ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ហាប្រឈម និងសំណូមពរ
## ទៅថ្នាក់ដឹកនាំ ក្រសួង និងអាជ្ញាធរពាក់ព័ន្ធ

# លើកកម្ពស់ សិទ្ធិអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុត ពីការបៀតបៀន គ្រប់ទម្រង់

ថ្ងៃទី២៥ ខែវិច្ឆិកា
ដល់ថ្ងៃទី១០ ខែធ្នូ
ឆ្នាំ២០២៤

យុទ្ធនាការ ១៦ ថ្ងៃ



# លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុតពីការបៀតបៀនគ្រប់ទម្រង់

## ញត្តិអំពីតម្រូវការចាំបាច់ និងបន្ទាន់

យើងទាំងអស់គ្នាជាតំណាង សមាគម សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រីលើវិស័យការងារចម្រុះ ដូចជាឧស្សាហកម្មកាត់ដេរ ចំណីអាហារ សេវាកម្ម កសិ-ស្បៀងអាហារ សេដ្ឋកិច្ចក្រៅប្រព័ន្ធ កម្មករសណ្ឋាគារ កាស៊ីណូ សំណង់ កម្មករធ្វើការងារតាមផ្ទះ កសិករ សហគមន៍ដីធ្លី អ្នករស់នៅក្នុងតំបន់មិនទាន់អភិវឌ្ឍន៍ និងបណ្តាញយុវជន បានរួមសហការគ្នារៀបចំយុទ្ធនាការ១៦ថ្ងៃ ឆ្នាំ២០២៤ ក្រោមប្រធានបទ៖ **«លើកកម្ពស់សិទ្ធអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុតពីការបៀតបៀនគ្រប់ទម្រង់»**។

យើងខ្ញុំកត់សម្គាល់នូវកិច្ចខិតខំប្រឹងប្រែង និងភាពរីកចម្រើននានារបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ទន្ទឹមនឹងនេះ យើងខ្ញុំដែលកំពុងធ្វើការផ្ទាល់ជាមួយក្រុមស្ត្រី និងក្មេងស្រី ក្នុងវិស័យចម្រុះដែលបានលើកឡើងខាងលើ សង្កេតឃើញថា ការរើសអើង ការគំរាមកំហែង និងអំពើហិង្សាគ្រប់ទម្រង់កើតមានឡើងដោយមិនស្មើភាពមកលើស្ត្រី និងក្មេងស្រី ជាពិសេសអ្នកស្រលាញ់ភេទដូចគ្នា ស្ត្រី និងក្មេងស្រីមានពិការភាព ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច សកម្មជនស្ត្រីដែលជាតំណាងអង្គការសង្គមស៊ីវិល សហជីព សកម្មជនដីធ្លី គណបក្សនយោបាយ និងបរិស្ថាននៅតែបន្តកើតមានឡើងគួរឱ្យកត់សម្គាល់ នៅគ្រប់ទីកន្លែង រួមមាន នៅក្នុងផ្ទះ នៅក្នុងសហគមន៍ នៅតាមកន្លែងធ្វើការ នៅតាមទីសាធារណៈ និងថ្មីៗនេះមានទាំងតាមប្រព័ន្ធបច្ចេកវិទ្យា និងបណ្តាញសង្គមផងដែរ។

អាស្រ័យដូច្នេះ យើងខ្ញុំជាតំណាង សមាគម បណ្តាញ សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោមនេះ សូមដាក់ជូនជាថ្មីនូវបញ្ជីតម្រូវការ និងដំណោះស្រាយជាអាទិភាព ចំនួន ១៦ ចំណុច ដែលយើងខ្ញុំធ្លាប់បានលើកឡើង និងដាក់ជូនរាជរដ្ឋាភិបាល តាមរយៈក្រសួងពាក់ព័ន្ធ និងអ្នកតាក់តែងគោលនយោបាយកាលពីឆ្នាំមុនរួចមកហើយ។ យើងខ្ញុំសូមកោតសរសើរនូវវឌ្ឍនភាព និងការឆ្លើយតបជាវិជ្ជមានពីសំណាក់រាជរដ្ឋាភិបាលនូវដំណោះស្រាយជាអាទិភាពមួយចំនួនក្នុងឆ្នាំកន្លងទៅ ហើយក៏បានធ្វើបច្ចុប្បន្នភាពដកចេញពីក្នុងបញ្ជីនេះដែរ។ ចំណែកឯដំណោះស្រាយជាអាទិភាពដូចលើកឡើងខាងក្រោមនេះ យើងខ្ញុំនៅមិនទាន់ឃើញមានភាពរីកចម្រើន និងមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។ ឆ្លៀតក្នុងឱកាសដែលរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងប្រទេសដទៃទៀតក្នុងតំបន់ និងក្នុងសកលលោកទាំងមូលកំពុងចូលរួមពិនិត្យ និងឆ្លុះបញ្ចាំងលើការអនុវត្តផែនការសកម្មភាពទីក្រុងប៉េកាំងក្នុងរយៈពេល ៣០ ឆ្នាំ មកនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការចាត់

ជាអាទិភាពដើម្បីឆ្លើយតបនូវតម្រូវការ និងដំណោះស្រាយខាងក្រោមនេះ ប្រកបដោយប្រសិទ្ធភាពគឺជាការរួមចំណែកដ៏សំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា ឈានឆ្ពោះទៅកាន់ការសម្រេចបានជោគជ័យ ចំពោះកិច្ចខិតខំប្រឹងប្រែងនានាកន្លងមក ក្នុងការតាក់តែង និងអនុវត្តច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិនានា ព្រមទាំងបង្ហាញជាសកលនូវការទទួលខុសត្រូវនៃកាតព្វកិច្ចរបស់រដ្ឋ ចំពោះការប្តេជ្ញាចិត្តជាសកល និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដើម្បីលើកកម្ពស់សមភាពយេនឌ័រលើគ្រប់វិស័យ ជាពិសេសគោលដៅទី ៥ នៃផែនការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០។

**តម្រូវការទី ១** ជំរុញពន្លឿនទាំងបរិមាណនៃការបង្កើតមត្តេយ្យសហគមន៍ និងទារកដ្ឋានឱ្យមានគុណភាពនៅតាមសហគមន៍ និងកន្លែងការងារ។

**តម្រូវការទី ២** ពន្លឿនការធ្វើវិសោធនកម្មច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបច្ចុប្បន្ន និងបង្កើតឱ្យមានជម្រកសុវត្ថិភាពរបស់រដ្ឋ សម្រាប់ស្ត្រីរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារ ស្ត្រីជាកម្មករធ្វើ ការងារតាមផ្ទះ កម្មករចំណាកស្រុក និងស្ត្រីនៅតាមសហគមន៍ ។

**តម្រូវការទី ៣** ចាត់វិធានការផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាព និងតឹងរឹងចំពោះអំពើហិង្សា និងការបៀតបៀន គ្រប់ទម្រង់មកលើស្ត្រី ដោយគ្មានការលើកលែង។

**តម្រូវការទី ៤** បញ្ឈប់ការចោទប្រកាន់ លាបពណ៌ផ្នែកនយោបាយ និងប្រើប្រាស់អំពើហិង្សាលើស្ត្រីសកម្មជន អ្នកការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី សិទ្ធិបរិស្ថាន សិទ្ធិការងារ និងសកម្មជនសង្គមផ្សេងទៀត។

**តម្រូវការទី ៥** ធ្វើកំណែទម្រង់ និងពង្រឹងសុវត្ថិភាពស្តង់ដានៃមធ្យោបាយដឹកជញ្ជូនកម្មករក្នុង វិស័យវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង។

**តម្រូវការទី ៦** កែលម្អលក្ខខណ្ឌការងារ និងពង្រឹងយន្តការការពារអ្នកធ្វើការងារតាមផ្ទះ។

**តម្រូវការទី ៧** ពង្រឹងយន្តការការពារសិទ្ធិពលករចំណាកស្រុកពីការកេងប្រវ័ញ្ចពលកម្ម ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប។

**តម្រូវការទី ៨** ពង្រឹង និងពង្រីកវិសាលភាពនៃប័ណ្ណសមាជិក ប.ស.ស. តាមរយៈការចុះធ្វើអធិការកិច្ច និងជំរុញឱ្យមានការចុះបញ្ជី និងបង់វិភាគទាន ប.ស.ស. ក្នុងចំណោមនិយោជក ជាពិសេស កម្មករនៅក្នុងវិស័យសំណង់ កសិ-ស្បៀងអាហារ និងរោងចក្រកាត់ដេរ វាយនភណ្ឌ ដែលធ្វើការក្រោមកុងត្រាដេរបន្ត (Sub-Contract)។

តម្រូវការទី ៩ ហាមឃាត់គ្រប់ទម្រង់នៃពលកម្មកុមារ និងធានាឱ្យមានការគាំពារសង្គម និងការពារសុវត្ថិភាពសម្រាប់កម្មករក្នុងវិស័យសំណង់ និងឡឥដ្ឋ។

តម្រូវការទី ១០ កសិករខ្នាតតូច ជាពិសេសកសិករជាស្ត្រី ទទួលបាននូវយុត្តិធម៌ សុខុមាលភាព សមធម៌ និងនិរន្តរភាពក្នុងប្រព័ន្ធស្បៀងអាហារ និងកិច្ចគាំពារសង្គមជាសកល។

តម្រូវការទី ១១ ផ្តល់ទីកន្លែងច្បាស់លាស់សម្រាប់អ្នកលក់ដូរតូចតាចតាមចិញ្ចើមផ្លូវ នៅតាមផ្សារ តាមឆ្នេរ និងតំបន់ទេសចរណ៍។

តម្រូវការទី ១២ ពង្រឹងគុណភាពនៃការបង្រៀនក្នុងម៉ោងរដ្ឋ បង្កើនចំនួនអាហារូបករណ៍សម្រាប់ជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងកន្លែងស្នាក់នៅឥតគិតថ្លៃ ជាពិសេសចំពោះសិស្សស្រី និងជនជាតិដើមភាគតិច។

តម្រូវការទី ១៣ បង្កើន និងពន្លឿនកិច្ចអន្តរាគមន៍ជួយដល់ស្ត្រីរងគ្រោះ ជាពិសេស ស្ត្រីមានពិការភាព ក្នុងការទទួលសេវាថែទាំ សុខភាព និងគាំទ្រផ្លូវច្បាប់ឱ្យទាន់ពេលវេលា។

តម្រូវការទី ១៤ ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គម និងប្រកាសបេឡាជាតិសន្តិសុខសង្គម ដោយកែសម្រួលលក្ខខណ្ឌតម្រូវឱ្យនិយោជកនៃសហគ្រាស នោះបានបង់ប្រាក់ភាគទាន ៩ ដង ក្នុងរយៈពេល១២ខែ ទើបកម្មករជាស្ត្រីមានផ្ទៃពោះទទួលបាន ប្រាក់ឧបត្ថម្ភ ៧០%នៃប្រាក់ជាប់ភាគទាន។

តម្រូវការទី ១៥ ពង្រីកទីផ្សារការងារក្នុងស្រុក បង្កើនជំនាញថ្មី រួមទាំងពន្លឿនការអនុវត្តគោលនយោបាយ ផ្តល់ប្រាក់ឧបត្ថម្ភ អំឡុងពេលបាត់បង់ប្រាក់ចំណូល ឬអត់ការងារធ្វើ ដោយផ្តោតជាពិសេស លើស្ត្រី និងយុវជន។

តម្រូវការទី ១៦ ពន្លឿនការចុះបញ្ជីពលរដ្ឋដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការធ្វើនិរាករណ៍ ប្រកាសអន្តរក្រសួង ៤០៤។

យើងខ្ញុំសូមធ្វើការបរិយាយលម្អិតពីដំណោះស្រាយជាក់លាក់ ចំពោះតម្រូវការនីមួយៗដូចខាងក្រោម៖

# តម្រូវការទី ១



## ជំរុញពន្លឿនទាំងបរិមាណនៃការបង្កើតមត្តេយ្យសហគមន៍ និងទារកដ្ឋានឱ្យមានគុណភាពនៅតាមសហគមន៍ និងកន្លែងការងារ។

### បញ្ហាដែលកើតមានឡើង៖

- យោងតាមរបាយការណ៍ ILO គិតត្រឹមឆ្នាំ២០១៨ ចំនួនពលកម្មស្ត្រីបានកើនឡើងប្រមាណ ៤៨% នៃកម្លាំងពលកម្មសរុបរបស់កម្ពុជាគឺមានន័យថាប្រហែល ៨០% នៃចំនួនស្ត្រីសរុបនៅកម្ពុជាបានចូលរួមសកម្មភាពក្នុងទីផ្សារការងារដែលមានចំណូល។ ដោយឡែក នៅមានស្ត្រីផ្សេងទៀតដែលមិនបានរាប់បញ្ចូលក្នុងរបាយការណ៍នេះ។ តួយ៉ាងទាំងស្ត្រីជនបទ ស្ត្រីចំណាកស្រុក កម្មករស្ត្រី និងស្ត្រីប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជួបនូវបញ្ហាលំបាកពេលលក់ដូរតាមដងផ្លូវ និងបំពេញការងារ។ ពួកគាត់ត្រូវដាក់កូនតូចតាមរទេះរុញ កណ្តៀតកូនបណ្តើរធ្វើការងារបណ្តើរ ត្រូវផ្ញើរកូនជាមួយអ្នកជិតខាង និងត្រូវទុកកូនតូចឱ្យនៅផ្ទះម្នាក់ឯង ឬទុកជាមួយឪពុកម្តាយចាស់ជរា ឬសាច់ញាតិដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព សុខភាព និងការលូតលាស់របស់កុមារ។

- ការសន្យារបស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងឆ្នាំ២០១៩ ថា ក្រសួងបន្តជ្រើសរើសវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាសម្រាប់ឆ្នាំ២០២០ ចំនួន ២០០ កន្លែង និងឆ្នាំ២០២១ ចំនួន ២០០ កន្លែងបន្ថែមទៀតពីចំនួនមត្តេយ្យសហគមន៍សរុបចំនួន ៣ ពាន់កន្លែងក្នុងចន្លោះឆ្នាំ២០២០-២០២១។ ដោយឡែក នៅក្នុងតំបន់គោលដៅដែលយើងបានធ្វើការជាមួយស្ត្រីជនបទ កម្មករស្ត្រី ស្ត្រីចំណាកស្រុក និងស្ត្រីប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនទាន់ទទួលបានការរាយការណ៍ថា នៅក្នុងសហគមន៍ដែលពួកគាត់កំពុងរស់នៅមានមត្តេយ្យសហគមន៍ដែលមានស្តង់ដាដូចក្រសួងអប់រំ យុវជន និងកីឡាលើកឡើង ដោយស្របទៅតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដែលបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ នោះទេ។

- យោងតាមច្បាប់ការងារ មាត្រា១៨៦ តម្រូវឱ្យនិយោជកដែលជួលកម្មករស្ត្រីចាប់ពី ១០០ នាក់ឡើងបង្កើតទារកដ្ឋាន ប៉ុន្តែកន្លែងធ្វើការភាគច្រើនមិនទាន់បានបង្កើតទារកដ្ឋានទេ។

- គោលនយោបាយបង្កើតទារកដ្ឋាន និងមត្តេយ្យសហគមន៍ ត្រូវបានអនុម័តឱ្យប្រើប្រាស់កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០២៣ និងយោងតាមការចុះផ្សាយរបស់ការសែតកម្ពុជាថ្មី កាលពីថ្ងៃ៣០ ខែធ្នូ ឆ្នាំ២០២៣ គិតរហូតមកដល់ឆ្នាំ២០២៣ នេះ រោងចក្រកាត់ដេរជាង ៧០០ កន្លែង ក្នុងចំណោមរោងចក្រកាត់ដេរប្រមាណជាង ៩០០ កន្លែង នៅទូទាំងប្រទេស មានទារកដ្ឋានសម្រាប់មើលថែទាំកូនៗ កម្មករ-និយោជិត ដោយឡែកនៅក្នុងគោលដៅ រោងចក្រសហគ្រាសដែលយើងបាននឹងកំពុងធ្វើការជាមួយ មិនទាន់មានទារកដ្ឋានគ្រប់ ហើយសម្រាប់រោងចក្រដែលមានទារកដ្ឋាននៅមិនទាន់ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កម្មករ-កម្មការនីនៅឡើយទេ។ បើតាមការសិក្សាមួយរបស់ការិយាល័យអង្គការអន្តរជាតិខាងការងារប្រចាំអាស៊ី និងប៉ាស៊ីហ្វិក ស្ត្រី១០នាក់ក្នុងចំណោម១០នាក់ដែលបានសម្ភាសន៍លើកឡើងថារោងចក្ររបស់ខ្លួនមិនមានទារកដ្ឋាននោះទេ ហើយមាន២នាក់ ក្នុងចំណោម១០នាក់ បានអះអាងថាការបំបៅដោះមិនអនុញ្ញាតទេក្នុងរោងចក្រខ្លួន។

## ដំណោះស្រាយ៖

- ស្នើក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវដាក់កំហិត និងធ្វើអធិការកិច្ចឱ្យបានដិតដល់គ្រប់គ្រឹះស្ថានការងារដែលបានជួលកម្មករនិយោជិតចាប់ពី ១០០ នាក់ឡើង និងចេញរបាយការណ៍ជាសាធារណៈពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និងលទ្ធផលលើកិច្ចការងារនេះ។

- ស្នើក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវដាក់ចេញនូវវិធានការអនុវត្តជាក់លាក់ឱ្យគ្រឹះស្ថានការងារដែលមានជួលបុគ្គលិកចាប់ពី ១០០នាក់ឡើង បង្កើតឱ្យមានទារកដ្ឋានសម្រាប់កុមារដែលមានអាយុចាប់ពី៣ខែ រហូតដល់អាយុចូលមត្តេយ្យនៅតាមគ្រឹះស្ថានការងារ។

- ក្រសួងអប់រំ យុវជន និងកីឡាបង្កើត ពង្រឹង និងពង្រីកមត្តេយ្យសហគមន៍នៅគ្រប់ឃុំ/សង្កាត់ដោយគិតគូរ និងដាក់ចេញនូវវិធានការជាក់លាក់ និងឱ្យបានគ្រប់ជ្រុងជ្រោយលើគុណភាពអប់រំជាចម្បង។



# តម្រូវការទី ២



## ពន្លឿនការធ្វើវិសោធនកម្មច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបច្ចុប្បន្ន និងបង្កើតឱ្យមានជម្រកសុវត្ថិភាពរបស់រដ្ឋ សម្រាប់ស្ត្រីរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ស្ត្រីជាកម្មករធ្វើការងារតាមផ្ទះ កម្មករចំណាកស្រុក និងស្ត្រីនៅតាមសហគមន៍។

### បញ្ហាដែលកើតមានឡើង៖

- ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារបច្ចុប្បន្ននៅមានចំនុចខ្វះខាត និងមិនទាន់ផ្តល់នូវការការពារគ្រប់ជ្រុងជ្រោយដល់ជនរងគ្រោះនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកិច្ចការនារីក៏បានបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់នេះនៅក្នុងរបាយការណ៍ជាតិលើកទី៦ ទៅកាន់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ី-ដ ឆ្នាំ២០១៨ និងដាក់បញ្ចូលក្នុងផែនការសកម្មភាពជាតិលើកទី ៣ ស្តីពីការទប់ស្កាត់ អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) និងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សា លើកុមារ (២០១៧-២០២១)។ នៅឆ្នាំ២០១៩ គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ី-ដ ក៏បានដាក់ចេញនៅក្នុងសេចក្តីអង្កេតសន្និដ្ឋានជាអាទិភាពរបស់ខ្លួនសម្រាប់រយៈពេលតាមដាន២ឆ្នាំបន្ទាប់ (ត្រឹមឆ្នាំ ២០២១) សម្រាប់រាជរដ្ឋាភិបាលកម្ពុជារាយការណ៍ត្រឡប់ចំពោះការធ្វើវិសោធនកម្មច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារបច្ចុប្បន្នដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានខកខានក្នុងការសម្រេចបានលើការអនុវត្តសេចក្តីអង្កេតសន្និដ្ឋាននេះ ហើយបានពន្យាពេលរហូតមកដល់បច្ចុប្បន្នដោយធ្វើការអនុវត្តជំនួសវិញក្នុងការផ្តួចផ្តើមបង្កើតនូវផែនទីបង្ហាញទិសក្នុងការធ្វើវិសោធនកម្មច្បាប់នេះ និងប្រើប្រាស់ធនធានលើកិច្ចការពិនិត្យឡើងវិញចំពោះសេចក្តីពន្យល់ខ្លឹមសារនៃច្បាប់អំពើហិង្សាក្នុងគ្រួសារបច្ចុប្បន្នទៅវិញ។

- កង្វះមណ្ឌល ឬផ្ទះសុវត្ថិភាពសម្រាប់ជនគ្រងគ្រោះនៅតែជាបញ្ហា និងជាឧបសគ្គដ៏ចម្បងមួយដើម្បីការពារសុវត្ថិភាព ជនរងគ្រោះពីការបន្តប្រើអំពើហិង្សា និងគំរាមកំហែងនានា។ នៅក្នុងប្រទេសកម្ពុជាមានមណ្ឌលសុវត្ថិភាពចំនួន ១៥ ប៉ុណ្ណោះគិតត្រឹម ឆ្នាំ២០២៤ ដែលមណ្ឌលទាំងអស់ស្ថិត

នៅក្រោមការគ្រប់គ្រងចាត់ចែងដោយអង្គការក្រៅរដ្ឋាភិបាលដែលជាទូទៅមិនមានលទ្ធភាពទទួលស្ត្រី និងកុមារីរងគ្រោះបានទូលំទូលាយជាទូទៅនោះទេ ដោយសារធនធានមនុស្ស និងថវិកាមានកំណត់។ ដើម្បីធានាឱ្យមានសេវាសង្គមគ្រប់ជ្រុងជ្រោយ និងមានមណ្ឌលសុវត្ថិភាពគ្រប់គ្រាន់ និងអាចរស្វែងរកបានសម្រាប់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រ ឬកម្មករស្ត្រីធ្វើការងារតាមផ្ទះ រដ្ឋាភិបាលគួរបែងចែកថវិការបស់រដ្ឋដើម្បីបង្កើតមណ្ឌលសុវត្ថិភាពឱ្យបានគ្រប់ខេត្តក្រុង និងតាមសហគមន៍ប្រកបដោយគុណភាព ។

## ដំណោះស្រាយ៖

- ពន្លឿន និងចាត់ជាអាទិភាពចំពោះដំណើរការធ្វើវិសោធនកម្មទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារទៅតាមអនុសាសន៍របស់គណៈកម្មាធិការរបស់អង្គការសហប្រជាតិទទួលបន្ទុកលើអនុសញ្ញាស៊ីដ។
- បែងចែកថវិកា និងធនធានរបស់រដ្ឋសម្រាប់ការបង្កើតមណ្ឌល/ផ្ទះសុវត្ថិភាព ដោយផ្តល់នូវសេវាគ្រប់ជ្រុងជ្រោយ និងប្រកបដោយគុណភាពសម្រាប់ជនរងគ្រោះអំពើហិង្សាដោយផ្អែកលើយេនឌ័ររួមមានទាំងការផ្តល់សេវាប្រឹក្សាផ្លូវចិត្ត ផ្លូវច្បាប់ ការគាំទ្រលើដំណើរការផ្លូវច្បាប់ និងការការពារសន្តិសុខដល់ស្ត្រីរងគ្រោះ និងកូនៗរបស់ពួកគេផងដែរ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយចំពោះប្រព័ន្ធរាយការណ៍ករណីអំពើហិង្សាផ្អែកលើយេនឌ័រដែលដាក់ឱ្យដំណើរការ ហើយធានាថាមានវត្តមានមន្ត្រីដែលទទួលបន្ទុកទទួលព័ត៌មាននេះជាប្រចាំ និងដោយមានការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ និងរក្សាឱ្យបាននូវការសម្ងាត់អំពីអត្តសញ្ញាណរបស់អ្នករាយការណ៍។



# តម្រូវការទី ៣



## ចាត់វិធានការផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាព និងតឹងរឹងចំពោះអំពើហិង្សា និងការបៀតបៀនគ្រប់ទម្រង់មកលើស្ត្រី ដោយគ្មានការលើកលែង។

### បញ្ហាដែលកើតមានឡើង៖

- ស្ត្រីនៅក្នុងសេវាកម្សាន្ត ម៉ាស្សា ផ្សព្វផ្សាយស្រាបៀរ កាស៊ីណូ និងអ្នករៀបបន្ទប់តាមផ្ទះសំណាក់ ឬសណ្ឋាគារប្រឈមនូវការបៀតបៀនរាងកាយ ការចាប់បង្ខំ និងហិង្សាផ្លូវភេទពីសំណាក់អតិថិជន អ្នកគ្រប់គ្រង ឬថៅកែ ហើយកន្លងមកមិនមានដំណោះស្រាយក្រៅតែពីឱ្យកម្មករទ្រាំបន្តទទួលយកនូវអំពើហិង្សានោះ បើមិនដូច្នោះត្រូវបញ្ឈប់ពីការងារ។ កន្លងមក ជនបង្កបានទទួលទោសពិន័យដោយគ្រាន់តែជាការទូទាត់សំណងរដ្ឋប្បវេណីទៅឱ្យជនរងគ្រោះ ដើម្បីជាថ្នូរនឹងការបញ្ចប់រឿង ហើយតែងតែរួចខ្លួនលើករណីព្រហ្មទណ្ឌដែលបង្ហាញពីកម្សោយនៃការអនុវត្តច្បាប់ និងជំរុញឱ្យអំពើហិង្សាលើស្ត្រីកើតមានជាបន្តបន្ទាប់។
- មានលក្ខខណ្ឌជាសម្ងាត់ដែលបាននឹងកំពុងកើតមានឡើងនៅក្នុងមជ្ឈមណ្ឌល ឬគ្រឹះស្ថានកម្សាន្តខារ៉ាអូខេ ពីសំណាក់អ្នកគ្រប់គ្រង និងនិយោជកដោយតម្រូវឱ្យកម្មករនិយោជិតជាស្ត្រីធ្វើតេស្តរកមើលថាមានផ្ទៃពោះ ឬអត់ និងដាក់លក្ខខណ្ឌឱ្យរំលូតកូន ឬត្រូវបណ្តេញចេញពីការងារ។
- បើទោះក្នុងច្បាប់ស្តីពីការងារបានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការចុះបញ្ជីជាមួយបេឡាជាតិសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ តែនិយោជកភាគច្រើននៅក្នុងវិស័យសេវាកម្សាន្តនេះមិនបានអនុវត្តទៅតាមច្បាប់នៅឡើយ។
- ក្រោយពីកូវីដ-១៩ បានបញ្ចប់កម្មករនៅក្នុងវិស័យសេវាកម្សាន្តប្រែក្លាយជាកម្មករមិនមានប្រាក់ឈ្នួលគោល មិនមានការងារទៀងទាត់ ហើយធ្វើការច្រើនម៉ោងដោយមិនមានការទូទាត់ប្រាក់សំណងលើការងារថែមម៉ោងនោះឡើយ។
- និយោជកមិនអន្តរាគមន៍ ហើយអាជ្ញាធរចាត់ទុកថាជារឿងធម្មតាចំពោះអំពើហិង្សា ការបៀតបៀនពីអតិថិជនមកលើស្ត្រីដែលធ្វើការនៅសេវាកម្មកម្សាន្ត។
- ករណីអំពើហិង្សាមានស្ថានភាពធ្ងន់ធ្ងររហូតដល់កម្មករមិនអាចទទួលយកបាន កម្មករទទួលបានការដោះស្រាយបានត្រឹមតែសម្របសម្រួលបញ្ចប់ដោយការផ្តល់ប្រាក់ជំងឺចិត្តបន្តិចបន្តួច ចំណែកជនល្មើសមិនត្រូវបានឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលត្រូវចាត់វិធានការសមស្របនានា ដោយតម្រូវឱ្យគ្រប់គ្រឹះស្ថានសេវាកម្សាន្ត បង្កើតនូវគោលនយោបាយប្រឆាំងអំពើបៀតបៀន និងអំពើហិង្សាគ្រប់រូបភាពមកលើស្ត្រី ដោយគិតពីសិទ្ធិសុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់កម្មករ និយោជិតមុនប្រាក់ចំណេញ។

- ក្រុមការងារអន្តរក្រសួងទទួលបន្ទុកលើសុខភាព និងសុវត្ថិភាពនៅកន្លែងការងារ ត្រូវធ្វើការត្រួតពិនិត្យតាមដានធានាថា គ្រប់គ្រឹះស្ថានមានគោលនយោបាយប្រឆាំងអំពើបៀតបៀន និងអំពើហិង្សាគ្រប់រូបភាពមកលើកម្មករស្ត្រី និងអន្តរាគមន៍ជាបន្ទាន់ជំរុញឱ្យនិយោជកអនុវត្តគោលនយោបាយនោះប្រកបដោយប្រសិទ្ធភាព។

- បេឡាជាតិសន្តិសុខសង្គមជំរុញឱ្យម្ចាស់គ្រឹះស្ថាន ឬសហគ្រាសសេវាកម្សាន្ត ជាពិសេសផ្នែកខារ៉ាអូខេ និងម៉ាស្សាអនុវត្តការចុះបញ្ជីនៅបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត។

- អធិការកិច្ចការងារត្រូវចុះត្រួតពិនិត្យ និងតាមដានគ្រប់គ្រឹះស្ថាន ឬសហគ្រាសសេវាកម្សាន្ត ដើម្បីធានានូវការការពារគ្មានលក្ខខណ្ឌរំលូតកូនដោយបង្ខំ និងការបណ្តេញចេញពីការងារដោយការរើសអើងលើស្ត្រីមានផ្ទៃពោះ ព្រមទាំងមានការដាក់ទោសទណ្ឌដល់និយោជកណាដែលបានប្រព្រឹត្តមកលើកម្មករនិយោជិតស្ត្រីក្នុងលក្ខខណ្ឌបែបនេះ។

- បង្កើតឱ្យបាននូវយន្តការច្បាស់លាស់អំពីការការពារកម្មករនិយោជិតពីអំពើហិង្សា និងការបៀតបៀននៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសដោយមានការចូលរួមពីតំណាងកម្មករនិយោជិត និងនិយោជក។

- រដ្ឋាភិបាលត្រូវប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលាយអំពីយន្តការនានាដែលជួយគាំទ្រពេលមានករណីរំលោភ បំពាន និងចាប់ជនល្មើសឱ្យទទួលខុសត្រូវទាំងរដ្ឋប្បវេណី និងទោសព្រហ្មទណ្ឌ។

- រដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សា និងការបៀតបៀននៅក្នុងពិភពការងារដែលគ្របដណ្តប់ដល់កម្មករនិយោជិតគ្រប់ប្រភេទ គ្រប់វិស័យ រួមទាំងនៅក្នុងសហគមន៍។



# តម្រូវការទី ៩



## បញ្ឈប់ការចោទប្រកាន់ លាបពណ៌ផ្នែកនយោបាយ និងប្រើប្រាស់អំពើហិង្សាលើស្ត្រីអ្នកការពារសិទ្ធិមនុស្ស សិទ្ធិដីធ្លី សិទ្ធិបរិស្ថាន សិទ្ធិការងារ និងសកម្មជនសង្គមផ្សេងទៀត។

### បញ្ហាដែលកើតមានឡើង៖

- មានការប្រើប្រាស់ប្រព័ន្ធតុលាការជាឧបករណ៍ ដើម្បីដាក់សម្ពាធ និងបំបិទសំឡេងរបស់ស្ត្រីសកម្មជនសិទ្ធិមនុស្ស តាមរយៈការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬចោទប្រកាន់ពីបទបរិហារកេរ្តិ៍ បទញុះញង់ ទោសក្បត់ជាតិ និងបទបំផ្លិចបំផ្លាញលើទ្រព្យសម្បត្តិឯកជន និងការចាប់ខ្លួនស្ត្រីជាដើម។
- មានការកើនឡើងជាច្រើនករណីចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងថ្នាក់ដឹកនាំសហជីពដែលអនុវត្តតួនាទី និងសិទ្ធិ សេរីភាពក្នុងការបញ្ចេញមតិតាមរយៈការធ្វើកូដកម្មដោយសន្តិវិធីបន្ទាប់ពីច្បាប់សហជីពត្រូវបានអនុម័តកាលពីឆ្នាំ ២០១៦។
- នៅរាល់ពេលដែលមានការផ្ទុះការតវ៉ារបស់កម្មករនិយោជិតប្រឆាំងនឹងការរំលោភបំពានពីសំណាក់ថៅកែ តំណាង សហជីពតែងត្រូវបានចោទប្រកាន់ថាបានញុះញង់កម្មករ រហូតដល់មានករណីខ្លះឈានដល់ការឃុំខ្លួនដូចករណី កូដកម្មនៅក្រុមហ៊ុនណាហ្គាវើលដ៍ដែលថ្នាក់ដឹកនាំសហជីពចំនួន ៨ រូបត្រូវបានឃុំខ្លួន និងនៅតែជាប់ទោស និងពន្ធនាគារ ក៏ដូចជាកាស៊ីណូមួយចំនួនទៀតនៅកំពង់សោមជាដើម។
- ច្បាប់កូវីដ-១៩ ក៏ត្រូវបានប្រើដើម្បីចោទប្រកាន់កម្មករដែលចូលរួមកូដកម្មផងដែរ ជាលទ្ធផលកូដករក្រុមហ៊ុន ណាហ្គាវើលដ៍ ត្រូវបានចាប់ដាក់ពន្ធនាគារកាលពីដើមខែកុម្ភៈ ឆ្នាំ២០២២ កន្លងមក។
- បើទោះបីជាក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័នមានចែងពីការការពារតំណាងសហជីពពីការរើសអើងដោយការយកហេតុផលសហជីពដើម្បីបញ្ឈប់ពីការងារ ប៉ុន្តែនិយោជកតែងបញ្ឈប់តំណាងសហជីពបានតាមអំពើចិត្ត ជាពិសេសនៅក្នុងវិបត្តិកូវីដ-១៩។

- គិតត្រឹមចុងខែកក្កដា ឆ្នាំ២០២៤ ក្មេងស្រីចំនួន ៣រូប ក្នុងចំណោម ១០រូប នៃសកម្មជនចលនាមាតាធម្មជាតិ ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ដោយសារតែភាពសកម្មក្នុងការការពារបរិស្ថាន និងយ៉ាងហោចណាស់ ៩៤រូប ត្រូវបានចាប់ខ្លួនដោយសារតែការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ ជុំវិញការរិះគន់ជាសាធារណៈលើគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ និងវៀតណាម ដែលក្នុងនោះមានយ៉ាងហោចណាស់ ៥៩រូប ជាសកម្មជនបរិស្ថាន សកម្មជនសិទ្ធិមនុស្ស និងសកម្មជនផ្សេងទៀត រួមទាំងកុមារផងដែរ។

## ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលដោះលែងសកម្មជនសិទ្ធិមនុស្ស បរិស្ថាន និងសកម្មជនផ្សេងទៀតដោយឥតលក្ខខណ្ឌ និងជំរុញឱ្យមានការអនុវត្តច្បាប់ដាច់ខាតដែលអនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្សជាសកល និងលើកកម្ពស់សិទ្ធិសេរីភាពជាមូលដ្ឋានដូចជា សិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំ សិទ្ធិក្នុងការចងក្រងសហជីព សិទ្ធិចូលរួម និងសិទ្ធិបង្កើតអង្គការ សមាគម ដោយគ្មានការយាយីរំខាន ការឃ្លាំមើល និងការជ្រៀតជ្រែកពីសំណាក់អាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ច។
- តុលាការត្រូវធានានូវឯករាជ្យភាព ស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ជាពិសេសមិនឈរលើអគតិទាំង៤ ដែលតែងតែដាស់តឿនសតិ និងការបម្រើតួនាទី ដោយសុចរិតភាព ស្មោះត្រង់ចំពោះមុខងាររបស់ខ្លួនដូចដែលបានធ្វើសច្ចាប្រណិធានមុនចូលកាន់តួនាទីនេះ។
- រាជរដ្ឋាភិបាលត្រូវធានានូវសិទ្ធិសេរីភាពក្នុងការសម្តែងមតិតាមរយៈការធ្វើកូដកម្ម និងបាតុកម្ម ដោយសន្តិវិធី។ ទម្លាក់ចោលបទចោទប្រកាន់ប្រឆាំងថ្នាក់ដឹកនាំសហជីពទាំងអស់ និងរដ្ឋាភិបាល ត្រូវអនុវត្តតាមស្មារតីអនុសញ្ញាស្នូល អង្គការអន្តរជាតិខាងការងារ ILO C87 និង C98 ដែលកម្ពុជាផ្តល់សច្ចាប័នដែលធានាសិទ្ធិក្នុងការបង្កើតសហជីព សិទ្ធិក្នុងការចរចាជា សមូហភាព និងសិទ្ធិក្នុងការធ្វើកូដកម្ម។
- ច្បាប់ទាំងឡាយណាដែលបង្កើតឡើងផ្ទុយពីស្មារតីរដ្ឋធម្មនុញ្ញ បង្កឱ្យមានភាពអយុត្តិធម៌ រាជរដ្ឋាភិបាលត្រូវលុបចោល ជំនួសមកវិញនូវច្បាប់ដែលផ្តល់ភាពយុត្តិធម៌ក្នុងសង្គម។



# តម្រូវការទី ៥



## កំណែទម្រង់និ ងពង្រឹងសុវត្ថិភាពស្តង់ដា នៃមធ្យោបាយដឹកជញ្ជូនកម្មករក្នុងវិស័យ វាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង។

### បញ្ហាដែលកើតមានឡើង៖

- នៅក្នុងយុទ្ធសាស្ត្រដើម្បីកាត់បន្ថយអត្រាគ្រោះថ្នាក់ការងារឆ្នាំ២០២៤-២០២៨ ប.ស.ស. បាន កំណត់នូវសកម្មភាព សិក្សា សហការ និងរៀបចំមធ្យោបាយធ្វើដំណើរសមរម្យសម្រាប់កម្មករនិយោជិត សំដៅលើកកម្ពស់កម្មវិធីបង្ការហានិភ័យការងារ ដោយត្រូវធ្វើបញ្ជីបច្ចុប្បន្នភាពអ្នកបើកបរយានយន្ត ដឹកកម្មករនិយោជិតជាប្រចាំ និងត្រូវសិក្សាពីជម្រើសក្នុងការជំរុញការផ្លាស់ប្តូររថយន្តកែច្នៃដែល ដឹកកម្មករនិយោជិតបច្ចុប្បន្នទៅជារថយន្តដឹកអ្នកដំណើរសម្រាប់ដឹកកម្មករនិយោជិត ដែលស្ថិត នៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬអង្គភាពណាមួយច្បាស់លាស់ យ៉ាងយូរត្រឹមឆ្នាំ២០២៧។ តែទោះជាយ៉ាងណា កន្លងមកឡានដឹកកម្មករនិយោជិតតែងតែរងគ្រោះថ្នាក់អំឡុងពេលធ្វើដំណើរ ដោយឡានទាំងនោះមិនមានការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឱ្យបានត្រឹមត្រូវ មិនមានកន្លែង អង្គុយដែលមានសុវត្ថិភាព កម្មករត្រូវឈរប្រជ្រៀតគ្នា និងអ្នកបើកបរឡានមានប្រើ ប្រាស់គ្រឿង ស្រវឹង។

- របាយការណ៍ របបបេឡាសន្តិសុខសង្គម បានឱ្យដឹងថា មានកម្មករចំនួន ៥៦៣ នាក់ រងរបួស និង ស្លាប់ ១០ នាក់ គិតត្រឹម ឆមាសទី១ ឆ្នាំ២០១៨។ របាយការណ៍នេះ ក៏បានបង្ហាញដែរថា ប្រហែល ២០ ភាគរយនៃអ្នកបើកបររថយន្តដឹកកម្មករក្នុងវិស័យកាត់ដេរមិនមានអាជ្ញាប័ណ្ណ។

### ដំណោះស្រាយ៖

- រាជរដ្ឋាភិបាលត្រូវបង្កើតគោលនយោបាយស្តីពីការដឹកជញ្ជូនកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើងដោយកំណត់ពីការរៀបចំឡានដឹកជញ្ជូនកម្មករដែលធានានូវផាសុខភាព និងសុវត្ថិភាពសម្រាប់កម្មករ ឬតម្រូវឱ្យនិយោជកទទួលរ៉ាប់រងក្នុងការជ្រើសរើសសេវាដឹកជញ្ជូន ដែលមានផាសុខភាព និងសុវត្ថិភាពសម្រាប់ផ្តល់ឱ្យកម្មករ។

# តម្រូវការទី ៦



## កែលម្អលក្ខខណ្ឌការងារ និងពង្រឹងយន្តការការពារអ្នកធ្វើការងារតាមផ្ទះ។

### បញ្ហាដែលកើតមានឡើង៖

- ចំនួនអ្នកធ្វើការងារតាមផ្ទះនៅក្នុងប្រទេសកម្ពុជាមានច្រើនប្រមាណ ២៥០,០០០នាក់ ហើយភាគច្រើនជាស្ត្រី ដោយឡែកច្បាប់ស្តីពីការងារមិនបានដាក់បញ្ចូលអ្នកធ្វើការងារតាមផ្ទះឡើយ។
- បើទោះបីក្រសួងការងារបានចេញប្រកាសលេខ ២៣៥ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីលក្ខខណ្ឌការងារសម្រាប់អ្នកធ្វើការតាមផ្ទះ ប្រការ១៣ បានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការចុះបញ្ជីជាមួយបេឡាជាតិសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ ដោយឡែករហូតមកដល់ពេលនេះម្ចាស់ផ្ទះ ភាគច្រើនមិនទាន់បានអនុវត្តទៅតាមប្រកាសនេះនៅឡើយទេ។ ម្យ៉ាងទៀត ប្រកាសនេះនៅមានចំនុចខ្វះខាតមួយចំនួនទៀត ដោយមិនទាន់បានបញ្ជាក់ពីប្រាក់ខែគោល កិច្ចសន្យាការងាររវាងម្ចាស់ផ្ទះ និងកម្មករ និងមិនបានដាក់បញ្ចូលនូវការឈប់សម្រាកលំហែមាតុភាពដោយមានប្រាក់ឈ្នួល និងសម្រាកបុណ្យជាតិផ្សេងៗ។

### ដំណោះស្រាយ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំរុញនិយោជកឱ្យចុះបញ្ជីរបបបេឡាជាតិសន្តិសុខសង្គមសម្រាប់កម្មករ អ្នកធ្វើការតាមផ្ទះ យោងតាមប្រកាស ២៣៥ ស្តីពីលក្ខខណ្ឌការងារអ្នកធ្វើការងារតាមផ្ទះ ចេញដោយក្រសួងការងារ ប្រការ១៣។
- ស្នើឱ្យក្រសួងការងារបង្កើតកិច្ចសន្យាគំរូជាលាយលក្ខណ៍អក្សររវាងម្ចាស់ផ្ទះជាមួយអ្នកធ្វើការតាមផ្ទះ ដែលស្របទៅតាមលក្ខខណ្ឌការងារ ការគោរពសិទ្ធិការងារ និងការការពាររួមទាំងអត្ថប្រយោជន៍ផ្សេងៗ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់អ្នកធ្វើការតាមផ្ទះ។
- ស្នើរាជរដ្ឋាភិបាលផ្តល់សច្ចាប័នអនុសញ្ញា ILO 189 ស្តីពីការការពារកម្មករធ្វើការងារតាមផ្ទះ ដើម្បីកម្មករធ្វើការងារតាមផ្ទះទាំងក្នុង និងក្រៅប្រទេសទទួលបាននូវការការពារសិទ្ធិ និងផលប្រយោជន៍ផ្សេងៗ។

# តម្រូវការទី ៧



## ពង្រឹងយន្តការការពារសិទ្ធិពលករចំណាកស្រុកពីការកេងប្រវ័ញ្ចពលកម្ម ការជួញដូរមនុស្ស និងទាសភាពសម័យទំនើប។

### បញ្ហាដែលកើតមានឡើង៖

- ការធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេស គឺជាសិទ្ធិ និងជម្រើសរបស់បុគ្គលម្នាក់ៗ ប៉ុន្តែតាមរយៈការសិក្សាកន្លងមកបង្ហាញថា ពលករកម្ពុជាភាគច្រើនបង្ខំចិត្តធ្វើចំណាកស្រុកដោយសារកត្តាជីវភាព ការជំពាក់បំណុល បញ្ហាដីធ្លីរ៉ាំរ៉ៃ ពុំមានការងារធ្វើក្នុងស្រុក ការចាញ់បោកមេខ្យល់ និងតម្លៃទិន្នផលកសិកម្មធ្លាក់ចុះជាដើម។ កត្តានេះ នាំឱ្យការធ្វើចំណាកស្រុករបស់ពួកគាត់មានភាពប្រថុយប្រថាន ងាយចាញ់បោកមេខ្យល់ឆ្លងដែន ដោយពុំមានឯកសារគ្រប់គ្រាន់ និងត្រូវចាប់ខ្លួនដោយអាជ្ញាធរនៅប្រទេសគោលដៅ។ គិតត្រឹមដើមឆ្នាំ ២០២២ មកដល់ពេលនេះ មានពលរដ្ឋកម្ពុជាចំនួន ២,១២១ នាក់ ឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ក្នុងនោះច្រើនជាង ៤០% ជាស្ត្រី និងកុមារតូចៗ។

- របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថាមានពលករកម្ពុជាចំនួន ១,៣០១,៦០៩ នាក់ កំពុងបម្រើការងារក្នុងប្រទេសគោលដៅចំនួន ៧ រួមមានប្រទេស ថៃ ម៉ាឡេស៊ី សឹង្ហបុរី ជប៉ុន កូរ៉េខាងត្បូង អារ៉ាប៊ីសាអូឌីត និងហុងកុង។ ប៉ុន្តែ តួលេខនេះមិនបានឆ្លុះបញ្ចាំងពីភាពជាក់ស្តែងនៃពលករកម្ពុជា ដែលចំណាកស្រុកតាមផ្លូវ មិនប្រក្រតី ឬដោយមិនមានឯកសារស្របច្បាប់នោះទេ។ កង្វះខាតទិន្នន័យ និងព័ត៌មានមិនគ្រប់គ្រាន់ អាចធ្វើឱ្យការឆ្លើយតបរបស់អាជ្ញាធរទៅនឹងតម្រូវការ និងបញ្ហាប្រឈមរបស់ពលករចំណាកស្រុកមិនបានគ្រប់ជ្រុងជ្រោយ និងមិនទាន់មានប្រសិទ្ធភាពខ្ពស់។

- មានការកើនឡើងគួរឱ្យកត់សម្គាល់នូវទម្រង់នៃការរើសអើង ការរំលោភបំពានសិទ្ធិការងារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម អំពើហិង្សាផ្នែកយេនឌ័រ និងបញ្ហាផ្សេងៗ មកលើក្រុមពលករចំណាកស្រុក ពិសេសអ្នកដែលមិនមាន ឯកសារស្របច្បាប់ និងពលករជាស្ត្រី។ ពលករស្ត្រីដែលធ្វើការក្នុងវិស័យសំណង់ ស្ត្រីមានផ្ទៃពោះត្រូវបានថៅកែបញ្ឈប់ការងារ មិនបើកប្រាក់ឈ្នួល ឬធ្វើការទទួលបានប្រាក់ឈ្នួលតិច និងមិនទាន់ទទួលបានគាំទ្រពេញលេញក្នុងកិច្ចគាំពារសង្គមនៅឡើយ។

- ពលករស្ត្រីដែលបម្រើការងារតាមផ្ទះវិញ រឹតតែប្រឈមនឹងបញ្ហាកាន់តែធ្ងន់ ពិសេសគឺពលកម្មដោយបង្ខំ ការដកហូតឯកសារ ការរំលោភសិទ្ធិការងារ អំពើហិង្សាលើរូបរាងកាយ ការរំលោភបំពានផ្លូវភេទ ការប៉ះពាល់ផ្លូវចិត្ត ព្រមទាំងមិន អាចស្វែងរកជំនួយអន្តរាគមន៍ផ្លូវច្បាប់បានទាន់ពេលវេលា។ លើសពីនេះទៅទៀត អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មមានសភាពប្រែប្រួល និងវិវត្តទៅរកទម្រង់ថ្មី ដោយមេខ្យល់ធ្វើការងារជាបណ្តាញ និងប្រើប្រាស់ប្រព័ន្ធសង្គមដើម្បីធ្វើការឆបោក និងលួងលោមជនរងគ្រោះដែលភាគច្រើនជាស្ត្រី និងកុមារ ដែលទន់ខ្សោយផ្នែកសេដ្ឋកិច្ចដើម្បីនាំឆ្លងដែលខុសច្បាប់ទៅចិនរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ល។

- របាយការណ៍ឆ្នាំ ២០២២ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ស្តីពីការជួញដូរមនុស្សប្រទេសកម្ពុជាបានរកឃើញថា កម្ពុជាត្រូវបានបញ្ចុះចំណាត់ថ្នាក់ទី ៣ លើសមត្ថភាពរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ អំពើពុករលួយដែលមានជាទូទៅនៅតែធ្វើឱ្យរាំងស្ទះដល់ការងាររបស់សមត្ថកិច្ច ក្នុងការចាប់ឱ្យជនល្មើសមាន ការទទួលខុសត្រូវ និងផ្តល់ការជួយដល់ជនរងគ្រោះ។ អាជ្ញាធរមិនបានធ្វើការស៊ើបអង្កេត ឬចាប់ឱ្យមន្ត្រីពាក់ព័ន្ធមានការទទួលខុសត្រូវពីបទព្រហ្មទណ្ឌក្នុងការឃុបឃិត ពិសេសឈ្មួញខិលខូច ដែលបានធ្វើឱ្យបុរស ជាពិសេសស្ត្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេស រងការជួញដូរមនុស្ស នៅតាមកន្លែងកំសាន្ត និងសិប្បកម្មឡូតដូ និងតាមប្រព័ន្ធអ៊ីនធឺណែត។ ដូច្នេះ មន្ត្រីបានខកខានក្នុងការផ្តល់សេវាការពារគ្រប់គ្រាន់ដល់ជនរងគ្រោះនៅក្នុងស្រុក និងនៅបរទេស ហើយពឹងផ្អែកខ្លាំងលើម្ចាស់ជំនួយបរទេស និងអង្គការសង្គមស៊ីវិលក្នុងការផ្តល់ការគាំពារចាំបាច់។

- នៅឆ្នាំ ២០២១ ក្រសួងយុត្តិធម៌បានរាយការណ៍ទិន្នន័យស្តីពីការកាត់ទោស និងដាក់ទោសលើករណីជួញដូរនៅគ្រប់ខេត្តទូទាំងប្រទេស។ តែដូចនៅក្នុងពេលមុនដែលសមត្ថកិច្ចតុលាការប្រហែលបានបញ្ចូលករណីរំលោភផ្លូវភេទ និងបទល្មើសដទៃទៀតនៅក្រៅនិយមន័យធម្មតានៃការជួញដូរនៅក្នុងទិន្នន័យរាយការណ៍។ ដូច្នេះ ចំនួនពិតនៃករណីស៊ើបអង្កេតកាត់ទោស និងដាក់ទោសលើការជួញដូរប្រហែលតិចជាងចំនួនដែលត្រូវបានរាយការណ៍។

## ដំណោះស្រាយៈ

- រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសគោលដៅត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីចំនួនពលករកម្ពុជា ពិសេសពលករជាស្ត្រី ដែលធ្វើការនៅប្រទេសគោលដៅ ដូចជានៅប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសគោលដៅដ៏ទៃទៀត។ លើសពីនេះ ក្រសួងគួររៀបចំឱ្យមាន ប្រព័ន្ធទិន្នន័យដែលត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយអំពីចំនួនពលករទៅតាមវិស័យការងារ អាសយដ្ឋានកន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់ពលករដែលអាចជួយឱ្យការអន្តរាគមន៍មានភាពឆាប់រហ័ស និងប្រសិទ្ធភាពខ្ពស់ នៅពេលដែលពលករមានបញ្ហា។

- សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលករចំណាកស្រុករួមមាន សិទ្ធិក្នុងការជួបជុំ សេរីភាពក្នុងការបញ្ចេញមតិ សេរីភាព ក្នុងការបង្កើតសមាគម គួរត្រូវបានធានាការពារ ហើយរាល់សកម្មភាពទាំងឡាយដែលជ្រៀតជ្រែក ឬគំរាមកំហែងទៅដល់សេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំរបស់ពលករត្រូវបញ្ឈប់ជាបន្ទាន់។

- រាជរដ្ឋាភិបាលត្រូវបង្កើតគណកម្មការចុះតាមដាន និងវាយតម្លៃទៅលើដំណើរការបញ្ជូនពលករនៅប្រទេសទទួលប្រចាំត្រីមាសដើម្បីធានាបានថាអនុស្សារណៈរវាងរដ្ឋនិងរដ្ឋនោះពិតជាបានអនុវត្តត្រឹមត្រូវ ជាពិសេស ពលករស្ត្រីបម្រើការងារតាមផ្ទះមានសិទ្ធិ និងសេរីភាពទទួលបាននូវការគោរពសិទ្ធិសេរីភាពជាមូលដ្ឋាន ការគាំពារសង្គម ព្រមទាំងសិទ្ធិកាន់កាប់ឯកសារផ្ទាល់ខ្លួន។ល។

- ស្ថានទូត ស្ថានកុងស៊ុលត្រូវបង្កើតមណ្ឌលសុវត្ថិភាពដើម្បីផ្តល់ការឆ្លើយតបបន្ទាន់ និងចាំបាច់នានាដល់ពលករដែលជួបបញ្ហា ពិសេសជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមមានការផ្គត់ផ្គង់អាហារ កន្លែងស្នាក់អាស្រ័យបណ្តោះអាសន្នដែលមានសុវត្ថិភាព ផ្តល់សេវាប្រឹក្សាយោបល់ និងជំនួយគាំពារផ្លូវច្បាប់ជាដើម។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីទូតនៅក្នុងប្រទេសគោលដៅ ចាំបាច់ត្រូវពង្រឹងកិច្ចសហការជាមួយអាជ្ញាធរក្នុងប្រទេសគោលដៅ និងភាគីពាក់ព័ន្ធក្នុងការទប់ស្កាត់ បង្ក្រាបបទល្មើស និងផ្តន្ទាទោសមេខ្យល់នៃអំពើជួញដូរមនុស្ស ការនាំឆ្លងដែនខុសច្បាប់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ (ពិសេសករណីទៅប្រទេសចិន)។

- ស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស ដោយគោរពតាមដំណើរការច្បាប់ត្រឹមត្រូវ និងដាក់ទណ្ឌកម្មចំពោះជនល្មើសក្នុងការជួញដូរផ្លូវភេទ និងជួញដូរពលកម្ម រួមទាំងមន្ត្រីឃុបឃិតដោយដាក់ទោសឱ្យជាប់ពន្ធនាគារធ្ងន់ធ្ងរតាមច្បាប់។

- បង្កើនការធ្វើអធិការកិច្ចការងារដោយមិនប្រកាសឱ្យដឹងមុននៅកន្លែងការងារដែលមានការប្រឈមខ្លាំង ពិសេសនៅតាមទីតាំងឡតដ្ឋ កន្លែងកម្សាន្ត ការដ្ឋានសំណង់ ចម្ការធំៗ កាស៊ីណូ ដោយផ្តោតសំខាន់លើការរកមើលករណីទាសភាពបំណុល ហើយចាប់ឱ្យថៅកែទទួលខុសត្រូវចំពោះមុខច្បាប់។



# តម្រូវការទី ៨



## ពង្រឹង និងពង្រីកវិសាលភាពនៃប័ណ្ណសមាជិក ប.ស.ស. តាមរយៈការចុះធ្វើអធិការកិច្ច និងជំរុញឱ្យមានការចុះបញ្ជី និងបង់វិភាគទាន ប.ស.ស. ក្នុងចំណោមនិយោជក ជាពិសេសកម្មករនៅក្នុងវិស័យសំណង់ កសិ-ស្បៀងអាហារ និងរោងចក្រកាត់ដេរវាយនភ័ណ្ឌ ដែលធ្វើការក្រោមកុងត្រាបន្ត (Sub-Contract)។

### បញ្ហាដែលកើតមានឡើង៖

- រោងចក្រប្រភេទស៊ីឈ្នួលដេរបន្ត (sub-contract factories) មានការកើនឡើងជាបន្តបន្ទាប់ និងមិនបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គមដែលធ្វើឱ្យកម្មករនិយោជិត (ជាពិសេសកម្មករដែលជាស្ត្រី) បាត់បង់ការទទួលបានការការពារ និងអត្ថប្រយោជន៍ផ្សេងៗដែលផ្តល់ជូនដោយច្បាប់របបសន្តិសុខសង្គម (ប.ស.ស.)។
- ការរើសអើងប្រឆាំងនឹងកម្មករនិយោជនជាស្ត្រីដែលមានផ្ទៃពោះ តាមរយៈការផ្តល់កិច្ចសន្យាការងារខ្លី ឬមិនផ្តល់កិច្ចសន្យាការងារថ្មីជូនពេលពួកគេត្រូវបានរកឃើញថាមានផ្ទៃពោះ។ ជាពិសេសទៀត រោងចក្រមិនបានផ្តល់អត្ថប្រយោជន៍តាមច្បាប់ និងចុះបញ្ជីជាមួយ ប.ស.ស.។ កត្តានេះបានធ្វើឱ្យកម្មករនិយោជិតដែលជាស្ត្រីជាច្រើននាក់បានបាត់បង់សន្តិសុខប្រាក់ចំណូល បាត់បង់សិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗ តាមរយៈប័ណ្ណសមាជិក ប.ស.ស. និងអាចរុញច្រានពួកគេធ្លាក់ទៅក្រោមបន្ទាត់នៃភាពក្រីក្រ និងវិសមភាពសង្គម។
- កម្មករនិយោជិតមួយចំនួនធំទទួលបានព័ត៌មាន ការបណ្តុះបណ្តាល និងចំណេះដឹងស្តីពី ប.ស.ស. និងគោលនយោបាយកិច្ចគាំពារសង្គមតាមរយៈសហជីព។ ប៉ុន្តែការរើសអើងសកម្មភាពសហជីព (ឧទាហរណ៍ ការរារាំង សកម្មភាព ឬបញ្ឈប់មេដឹកនាំសហជីព) បានធ្វើឱ្យលទ្ធភាពទទួលបានអត្ថប្រយោជន៍ និងការការពារពី ប.ស.ស. ដើរថយក្រោយ ត្បិតការទទួលបានព័ត៌មាន និងចំណេះដឹងស្តីពីរបបសន្តិសុខសង្គម ប.ស.ស. ក្នុងចំណោមកម្មករនិយោជិតនៅមានកម្រិត។
- ស្ថានភាពកម្មករដែលធ្វើការក្នុងប្រព័ន្ធទៅជាកម្មករក្រៅប្រព័ន្ធ ដោយសារពួកគាត់ត្រូវបានគេជួលឱ្យធ្វើការ បើកប្រាក់ ឈ្នួលប្រចាំថ្ងៃ គ្មានសន្តិសុខការងារ គ្មានសន្តិសុខប្រាក់ចំណូល ការងារមានហានិភ័យខ្ពស់ ត្បិតកន្លែងធ្វើការគ្មាន ការត្រួតពិនិត្យប្រព័ន្ធសុខភាព និងសុវត្ថិភាពសម្រាប់កម្មករនិយោជិក ជាពិសេសគឺមិនបានចុះបញ្ជី និងបង់វិភាគទានជាមួយបេឡាជាតិសន្តិសុខសង្គម ប.ស.ស.។

- ប្រាក់ឈ្នួលអប្បបរមាដែលមានស្រាប់ក្នុងវិស័យកាត់ដេរ និងស្បែកជើងមិនអនុវត្តចំពោះកម្មករក្នុងវិស័យកសិកម្មទេ។ កម្មករដែលធ្វើការនៅក្នុងចម្ការភាគច្រើនជាកម្មករដែលធ្វើការតាមរដូវ និងស្ថិតនៅក្រោមកុងត្រាបន្តដែលមិនមានប្រព័ន្ធការពារសុខភាព និងសុវត្ថិភាពត្រឹមត្រូវ។ នៅឆ្នាំ២០២១ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) បានពង្រីកប្រព័ន្ធគាំពារសង្គមដល់គ្រប់ប្រភេទកម្មករ រួមទាំងកម្មករនៅក្នុងវិស័យកសិកម្មផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មានសកម្មភាពតិចតួចបំផុតដែលបានអនុវត្តដើម្បីដោះស្រាយវិសាលភាពនៃការគ្របដណ្ដប់នេះ ឬដើម្បីជូនដំណឹងដល់កម្មករក្នុងវិស័យកសិកម្មអំពីនីតិវិធីនៃការចុះឈ្មោះដើម្បីទទួលបានអត្ថប្រយោជន៍បេឡាជាតិរបបសន្តិសុខសង្គមរបស់ពួកគេ។ កម្មករក្នុងវិស័យកសិកម្មភាគច្រើនបានរាយការណ៍ថាបានបង់ប្រាក់ចន្លោះពី ៥ ទៅ ៧,៥ ដុល្លារក្នុង មួយខែ តាមរយៈអ្នកដឹកនាំក្រុម ឬអ្នកគ្រប់គ្រង សម្រាប់ការធានារ៉ាប់រងរបស់បេឡាជាតិរបបសន្តិសុខសង្គម ប៉ុន្តែពួកគាត់មិនដឹងថាសម្រាប់គម្រោងមួយណា ហើយក៏មិនត្រូវបានគេជូនដំណឹងអំពីការរួមចំណែករបស់និយោជកផងដែរ។

## ដំណោះស្រាយ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលថ្នាក់ក្រោមជាតិសហការគ្នាពង្រឹងការចែករំលែកព័ត៌មាន និងការចុះធ្វើអធិការកិច្ចការងារតាមរោងចក្រនានា ជាពិសេសចម្ការធំៗ ដើម្បីកាត់បន្ថយរោងចក្រដែលស៊ីឈ្នួលដេរ និងម៉ៅការបន្ត និងដើម្បីជំរុញការបង់វិភាគទានជូនកម្មករនិយោជិតទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធានាការគោរពសិទ្ធិការងារ ជាពិសេសធានាការការពារចំពោះកម្មករនិយោជិតស្ត្រីដែលមានផ្ទៃពោះពីការរើសអើង និងបញ្ឈប់ពីការងារក្នុងកំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល។
- មន្ត្រីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) និងរដ្ឋបាលថ្នាក់ក្រោមជាតិចុះអធិការកិច្ចចំពោះរោងចក្រ និងចម្ការស៊ីឈ្នួលបន្ត ហើយត្រូវដាក់ទោសយ៉ាងតឹងរឹងចំពោះរោងចក្រកាត់ដេរទាំងឡាយណាដែលមិនមានចុះបញ្ជីបេឡាជាតិរបបសន្តិសុខសង្គម។
- បេឡាជាតិសន្តិសុខសង្គមដាក់កំហិត និងមានវិធានការជាក់លាក់ចំពោះកម្មករនិយោជិតនៃសហគ្រាស ឬគ្រឹះស្ថាន រួមទាំងរោងចក្រដែលស៊ីឈ្នួលដេរ និងអ្នកម៉ៅការដែលជួលកម្មករបន្ត មិនបានចុះបញ្ជីនៅពេលមានគ្រោះថ្នាក់ការងារ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដោយដាក់ទោស ឬផាកពិន័យទៅលើម្ចាស់រោងចក្រសហគ្រាស និងអ្នកម៉ៅការទាំងនោះ តែកម្មករត្រូវទទួលបានការព្យាបាលថែទាំស្របទៅតាមគោលនយោបាយរបបសន្តិសុខសង្គមនៅកម្ពុជា។
- ស្នើសុំបេឡាជាតិសន្តិសុខសង្គមពន្លឿនក្នុងការបញ្ជាក់ និងដាក់បញ្ចូលនូវជំងឺវិជ្ជាជីវៈក្នុងបណ្ណសមាជិក ប.ស.ស.។

# តម្រូវការទី ៩



## ហាមឃាត់គ្រប់ទម្រង់នៃពលកម្មកុមារ និង ធានាឱ្យមានការគាំពារសង្គម និងសុវត្ថិភាព សម្រាប់កម្មករក្នុងវិស័យសំណង់ និងឡឥដ្ឋ។

### បញ្ហាដែលកើតមានឡើង៖

- កម្មករជាស្ត្រី និងកុមារក្នុងវិស័យសំណង់ និងឡឥដ្ឋ បន្តរទទួលរងការរើសអើង និងកេងប្រវ័ញ្ច ធ្ងន់ធ្ងរពីលក្ខខណ្ឌការងារ និងបរិយាកាសការងារនៅកន្លែងធ្វើការ ដូចជាការទទួលបានប្រាក់កម្រៃទាប ធ្វើការដើម្បីដោះបំណុល ធ្វើការលើសកំលាំងពលកម្ម កង្វះការការពារសុវត្ថិភាពពីគ្រោះថ្នាក់ការងារ និងការបៀតបៀនផ្លូវភេទ។
- មិនមានការពង្រឹងប្រព័ន្ធចុះត្រួតពិនិត្យតាមដានលក្ខខណ្ឌការងារ សុខភាព និងសុវត្ថិភាពរបស់កម្មកក្នុងវិស័យសំណង់ និងឡឥដ្ឋប្រកបដោយតម្លាភាព និងប្រសិទ្ធភាពឡើយ។
- ក្រុមអ្នកម៉ៅការបន្តរគេចវេសពីការទទួលខុសត្រូវពេលកម្មករមានគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ នាំឱ្យកម្មករមួយចំនួនត្រូវប្រើប្រាស់ថវិកាផ្ទាល់ខ្លួនក្នុងការព្យាបាលជំងឺនៅពេលមានគ្រោះថ្នាក់ការងារ និងទិញសម្ភារៈការពារសុវត្ថិភាពរបស់ខ្លួន។

### ដំណោះស្រាយ៖

- ពង្រឹងការអនុវត្តច្បាប់ស្ដីពីការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងច្បាប់ការងារដោយដាក់ទោសទណ្ឌទៅ លើបុគ្គលដែលរកឃើញថាប្រព្រឹត្ត ឬផ្សំគំនិតក្នុងការប្រើប្រាស់ទាសភាពបំណុលនៅក្នុងឧស្សាហកម្មឡឥដ្ឋនៅក្នុងប្រទេសកម្ពុជា។
- ហាមឃាត់ដាច់ខាតនូវរាល់ទម្រង់ទាំងអស់នៃការងាររបស់កុមារអាយុក្រោម ១៨ ឆ្នាំ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក្នុងចង្វាក់ផលិតកម្មឡឥដ្ឋដោយមិនមានការលើកលែង ដែលស្រដៀងគ្នាទៅនឹងការហាមឃាត់គ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារក្នុងវិស័យដោះគ្រាប់មីន រ៉ែ និងការងារយកថ្មនៅក្នុងប្រកាសលេខ ១៦០ ស្ដីពីការហាមឃាត់កុមារធ្វើការងារនៅកន្លែងប្រកបដោយគ្រោះថ្នាក់។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បង្កើនការចុះអធិការកិច្ចឱ្យបានញឹកញាប់នៅតាមបណ្តាការដ្ឋានសំណង់ និងសិប្បកម្មឡូតដ្ឋ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពដោយមិនមានការជូនដំណឹងទៅម្ចាស់សិប្បកម្មជាមុន។

- បង្កើតឱ្យមានប្រាក់ឈ្នួលអប្បបរមាសមរម្យ និងពន្លឿនការអនុវត្តចុះបញ្ជី ប.ស.ស. របស់សហគ្រាសគ្រឹះស្ថាន ឱ្យបានឆាប់ និងមានប្រសិទ្ធភាពក្នុងវិស័យសំណង់ និងឡូតដ្ឋ ដោយធ្វើការហាមឃាត់ការផ្តល់កម្រៃជាប្រព័ន្ធទៅតាមចំនួនឥដ្ឋ ឬពលកម្មតាមថ្ងៃ និងធានាថាកម្មករដែលធ្វើការក្នុងវិស័យនេះទាំងអស់ទទួលបានកិច្ចសន្យាការងារ ដោយទទួលបានការការពារក្រោមច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជាដូចកម្មករនិយោជិតនៅក្នុងវិស័យផ្សេងដែរ។

- រាជរដ្ឋាភិបាលចេញប្រកាសស្តីពី សុខភាព និងសុវត្ថិភាពសម្រាប់កម្មករក្នុងវិស័យសំណង់ និងឡូតដ្ឋ ដោយដាក់ពិន័យចំពោះការដុតកាកសំណល់ពីឧស្សាហកម្មកាត់ដេរនៅក្នុងការផលិតឥដ្ឋដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសុខភាពរបស់កម្មករនិយោជិត និងសហគមន៍ជុំវិញ។

- រាជរដ្ឋាភិបាលចេញប្រកាសស្តីពីការគ្រប់គ្រង និងអធិការកិច្ចលើក្រុមហ៊ុនម៉ៅការបន្ត។



# តម្រូវការទី ១០



## កសិករខ្នាតតូច ជាពិសេសកសិករជាស្ត្រី បាននូវយុត្តិធម៌ សុខុមាលភាព សមធម៌ និងនិរន្តរភាពក្នុងប្រព័ន្ធស្បៀងអាហារ និងកិច្ចគាំពារសង្គមជាសកល។

### បញ្ហាដែលកើតមានឡើង៖

- ស្ត្រីកសិករ ស្ត្រីជនជាតិដើមភាគតិច និងកម្មករកសិកម្មជួបប្រទះបញ្ហាប្រឈមសំខាន់ៗ នៅពេលដែលវិស័យកសិកម្មឆ្ពោះទៅរក "ទំនើបភាវូបនីយកម្ម និងពាណិជ្ជកម្ម" ដែលកសិករបង្កើនការវិនិយោគកាន់តែច្រើន។ ជារឿយៗការណ៍ នេះបានបង្ខំពួកគាត់ឱ្យធ្វើការជ្រើសរើសការធ្វើចំណាកស្រុកមិនច្បាស់លាស់ ដោយសារតែការធ្លាក់ចូលទៅក្នុងចំណងបំណុល។ ស្ត្រីនៅជនបទជាច្រើនទុកកូនរបស់ពួកគាត់ឱ្យនៅជាមួយជីដូន ឬសាច់ញាតិ ឬនៅក្នុងសហគមន៍របស់ពួកគាត់ ដែលមានប្រព័ន្ធគាំពារសង្គមមិនគ្រប់គ្រាន់ ហើយប្រព័ន្ធគាំពារខ្លះមានសម្រាប់តែអ្នកដែលចាត់ថ្នាក់ជាគ្រួសារក្រីក្រប៉ុណ្ណោះ។
- តាមទស្សនៈយេនឌ័រ ស្ត្រីកសិករ និងស្ត្រីជនជាតិដើមភាគតិចមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងការធានាការទទួលស្គាល់សិទ្ធិរបស់ពួកគេចំពោះការផលិត និងគ្រប់គ្រងស្បៀងអាហារនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដូចជាកម្ពុជា។ ខណៈពេលដែលប្រព័ន្ធកសិកម្ម និងអាហារផ្តល់ឱកាសការងារដោយអាស្រ័យលើខ្លួនឯងយ៉ាងច្រើនសម្រាប់ស្ត្រីស្ត្រីកសិករ និងស្ត្រីជនជាតិដើមភាគតិច ពួកគេជារឿយៗខ្វះលទ្ធភាពទទួលបានការងារសមរម្យ និងជីវភាពសមរម្យ។ បញ្ហាប្រឈមធំៗរួមមានការចូលប្រើប្រាស់ដីមានកម្រិត ការគ្រប់គ្រងលើធនធានធម្មជាតិមានកម្រិត និងការចូលរួមផ្នែកនយោបាយ និងការតំណាងនៅក្នុងដំណើរការធ្វើការសម្រេចចិត្តនៅមិនទាន់គ្រប់គ្រាន់។
- កសិករខ្នាតតូច ជាពិសេសស្ត្រីនៅជនបទដែលជាក្រុមអ្នកផលិតស្បៀងអាហារពិតប្រាកដកំពុងប្រឈមលើបញ្ហាប៉ះ ពាល់សុខភាពនៅពេលដែលពួកគេប្រើប្រាស់ថ្នាំពុល ឬសារធាតុគីមីពុលនៅក្នុងដំណើរផលិតស្បៀងអាហារ ជាពិសេសចម្ការធំៗ។
- កសិករខ្នាតតូច ពិសេសស្ត្រីនៅជនបទប្រឈមមុខលើបញ្ហាថៃទាំសុខភាពក្នុងមុខរបររបស់ពួកគេដោយត្រូវចំណាយថវិកាច្រើនសម្រាប់ថៃទាំសុខភាព។

- គោលនយោបាយ និងប្រព័ន្ធគាំពារសង្គមមិនទាន់បានដាក់បញ្ចូល និងគិតគូរបានគ្រប់ជ្រុងជ្រោយ សម្រាប់កសិករខ្នាតតូច និងប្រជាជនជនបទ ជាពិសេសស្ត្រីនៅជនបទពីការទទួលបានអត្ថប្រយោជន៍ អំពីកម្មវិធីកិច្ចគាំពារសង្គមជាសកលនៅឡើយទេ។
- ពេលរដូវប្រមូលផល ត្រូវបានឈ្មួញកំណត់តម្លៃទីផ្សារថោក ធ្វើឱ្យកសិករគ្មានជម្រើស ដោយសារត្រូវបង់សងបំណុលដែលពួកគាត់បានខ្ចីមកប្រើប្រាស់ក្នុងដំណើរការផលិត។
- ការពិនិត្យតាមដានសុខភាពមិនត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីរបស់បេឡាជាតិសន្តិសុខសង្គមនោះទេ។ ជាក់ស្តែង ការទៅទទួលសេវាសុខភាពគឺលុះត្រាណាតែសមាជិកប័ណ្ណ ប.ស.ស. ឈឺ ឬមានគ្រោះថ្នាក់ការងារ។ កត្តានេះហើយ ដែលធ្វើឱ្យលទ្ធភាពព្យាករណ៍រោគសញ្ញាជំងឺ (early detection) ក្នុងវិស័យវិជ្ជសាស្ត្រ មិនត្រូវបានធ្វើឡើងសម្រាប់ប័ណ្ណសមាជិក ប.ស.ស.។

## ដំណោះស្រាយ៖

- រដ្ឋាភិបាលពិសេសក្រសួងកសិកម្មពង្រឹង និងលើកកម្ពស់កសិកម្មកេ្សត្របរិស្ថាន រួមទាំងពង្រឹងទីផ្សារក្នុងស្រុកតាមទីជនបទ ដែលការណ៍នេះនឹងផ្តល់នូវការពង្រឹងសិទ្ធិអំណាច និងការណ៍ដែលអាចអនុវត្តទៅបានរបស់កសិករខ្នាតតូច ជាពិសេសកសិករស្ត្រី ក្នុងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាបំរែបំរួលអាកាសធាតុ សុវត្ថិភាព និងសន្តិសុខស្បៀងនៅមូលដ្ឋាន និងទូទាំងប្រទេស។
- រដ្ឋាភិបាលដោះស្រាយបញ្ហាប្រឈមធំៗរួមមាន កសិករខ្នាតតូច ជាពិសេសកសិករស្ត្រី និងស្ត្រីជនជាតិដើមភាគតិច ចូលប្រើប្រាស់ដីកសិកម្ម គ្រប់គ្រងលើធនធានធម្មជាតិ និងចូលរួមផ្នែកនយោបាយ និងតំណាងនៅក្នុងដំណើរការ ធ្វើការសម្រេចចិត្តលើគោលនយោបាយកសិកម្ម។
- រដ្ឋាភិបាលត្រួតពិនិត្យឡើងវិញលើគោលនយោបាយក្របខណ្ឌកិច្ចគាំពារសង្គម និងដាក់បញ្ចូលកសិករខ្នាតតូចឱ្យទទួលបានកិច្ចគាំពារសង្គមជាពិសេសរបបថែទាំសុខភាព។
- ក្រុមប្រឹក្សាជាតិកិច្ចគាំពារសង្គមបង្កើតឱ្យមានតំណាងកសិករក្នុងដំណើរពិគ្រោះយោបល់ និងដាក់បញ្ចូលកសិករជាផ្លូវការក្នុងគោលនយោបាយគាំពារសង្គម។
- រដ្ឋាភិបាលត្រូវរៀបចំគោលនយោបាយជាក់លាក់ដើម្បីធ្វើការបណ្តុះបណ្តាលជំនាញកសិកម្ម និងត្រូវគាំទ្រឧបត្ថម្ភទុនលើកសិករខ្នាតតូច ជៀសវាងកសិករទៅខ្ចីគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការប្រាក់ខ្ពស់។
- រដ្ឋាភិបាលត្រូវអន្តរាគមន៍ពេលដែលកសិករប្រមូលផល បញ្ចៀសឈ្មួញឆក់ឱកាសបន្ទាបតម្លៃរបស់កសិករក្នុងស្រុក។

- រដ្ឋាភិបាលត្រូវពង្រីកប្រព័ន្ធធារាសាស្ត្រដែលអាចឱ្យប្រជាកសិករខ្នាតតូច ជាពិសេសកសិករស្ត្រី អាចប្រើប្រាស់បានក្នុងកិច្ចការងារអាស្រ័យផល និងបង្កបង្កើនផលកសិកម្មគ្រប់ទម្រង់។

- ស្នើសុំពង្រីកវិសាលភាពប័ណ្ណសមាជិត ប.ស.ស. ដោយដាក់បញ្ចូលកម្មវិធីត្រួតពិនិត្យតាមដានសុខភាព (early detection) និងបង្កើតកញ្ចប់ថវិកាព្យាបាលជំងឺ ទៅក្នុងរបបសន្តិសុខសង្គម ដើម្បីបង្ការ និងបញ្ចៀសផលជះអាក្រក់ដល់សុខភាព និងចំណាយច្រើនលើការព្យាបាល និងសេវាសុខភាព។

- រដ្ឋាភិបាលផ្តល់ឱ្យស្ត្រីមានផ្ទៃពោះធ្វើការទាំងក្នុង និងក្រៅប្រព័ន្ធដែលមានប័ណ្ណ ប.ស.ស. ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលស្មើរៗគ្នាដោយមិនមានការរើសអើង។



# តម្រូវការទី ១១



## ផ្តល់ទីកន្លែងសម្រាប់អ្នកលក់ដូរតូចតាចតាមចិញ្ចើមផ្លូវ ហើយផ្តល់នូវតម្លៃធូរថ្លៃ រួមមាននៅតាមផ្សារ តាមឆ្នេរ និងតំបន់ទេសចរណ៍។

### បញ្ហាដែលកើតមានឡើង៖

- អាជីវករលក់ដូរត្រូវបង់ថ្លៃមុខផ្ទះលក់ដូរមួយ ហើយនៅត្រូវបង់ភាស៊ីឱ្យសន្តិសុខច្រើននាក់ដែលមកយកថ្លៃភាស៊ីបន្តបន្ទាប់ និងមានករណីការដកហូតនូវទំនិញដែលត្រូវប្រកបរបរចិញ្ចឹមជីវិតដូចជាបន្លែ និងផ្លែឈើរបស់ពួកគាត់បន្ថែម ពីលើភាស៊ីទៀតផង។
- សន្តិសុខផ្សារបានរឹបអូសដកហូតបន្លែផ្លែឈើអាជីករទៅទុករយៈពេលយូរបណ្តាលឱ្យទំនិញរលួយ និងខូចខាតថវិកាក្នុងការប្រកបមុខរបរប្រចាំថ្ងៃ។
- សន្តិសុខផ្សារបអំពើហិង្សា ដោយគ្រវែង និងទាត់ទំនិញរបស់អាជីវករដែលលក់ដូរ ជាថ្នូរនឹងប្រាក់កម្រៃ បណ្តាលឱ្យប៉ះពាល់ដល់ជីវភាពរបស់គាត់។
- ការបណ្តេញអាជីវករពីទីតាំងលក់ដូរប្រចាំថ្ងៃ ដោយមិនមានផែនការក្នុងការផ្តល់ទីតាំងឱ្យគាត់លក់ច្បាស់លាស់ ឬលក់បណ្តោះអាសន្ន បណ្តាលឱ្យបាត់បង់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ និងប៉ះពាល់ដល់ជីវភាព និងការសិក្សាកូនៗនៅក្នុងបន្ទុក។

### ដំណោះស្រាយ៖

- ពន្លឿនការចុះបញ្ជីអាជីវករខ្នាតតូចក្នុងការទទួលបានការគាំពារសង្គម។
- រៀបចំកន្លែងលក់ដូរសម្រាប់អាជីវករតូចតាច មានតម្លៃសមរម្យដែលអាចឱ្យពួកគាត់ប្រកបរបរចិញ្ចឹមជីវិត និងគាំទ្រដល់សមាជិកគ្រួសារ ជាពិសេសកូនៗរបស់គាត់។
- ចាត់វិធានការយ៉ាងតឹងរឹងចំពោះសន្តិសុខផ្សារ និងអាជ្ញាធរដែលប្រើប្រាស់អំពើហិង្សាលើអាជីវករលក់ដូរតាមផ្សារ និងតាមដងផ្លូវ។
- កំណត់ទីតាំងឱ្យអាជីវករដែលលក់ដូរតាមតំបន់ទេសចរណ៍ក្នុងតម្លៃសមរម្យ ដែលអាចឱ្យគាត់មានចំណូលផ្គត់ផ្គង់គ្រួសារ និងបញ្ជូនកូនៗបានរៀនសូត្រ។
- បញ្ឈប់ការដកហូតបន្លែ ផ្លែឈើ ទុកនៅប៉ុស្តិ៍ ឬទីស្នាក់ការដែលទង្វើនេះបានធ្វើឱ្យអ្នកលក់ដូរតូចតាចបាត់បង់ទុនបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត។
- សូមការផ្តល់ឱ្យស្ត្រីមានផ្ទៃពោះទាំងក្នុងនិងក្រៅប្រព័ន្ធដែលមានប័ណ្ណ ប.ស.ស. ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលស្មើៗគ្នាដោយមិនមានការរើសអើង។

# តម្រូវការទី ១២



## ពង្រឹងគុណភាពនៃការបង្រៀនក្នុងម៉ោងរដ្ឋ បង្កើនចំនួនអាហារូបករណ៍សម្រាប់ជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងកន្លែងស្នាក់នៅឥតគិតថ្លៃ ជាពិសេសក្មេងស្រី និងជនជាតិដើមភាគតិច។

### បញ្ហាដែលកើតមានឡើង៖

- នៅតាមសាលារដ្ឋគ្រូបង្កើនម៉ោងបង្រៀនគួរដោយមិនផ្តោតលើគុណភាពនៃការអប់រំក្នុងម៉ោងសិក្សា ជាហេតុផលនាំឱ្យការអប់រំមិនមានគុណភាពសិស្សដែលមានជីវភាពក្រីក្រមិនមានលទ្ធភាពបង់ប្រាក់រៀនគួរ ហើយបាត់បង់ឱកាសក្នុងការបន្តការសិក្សា។
- សិស្សនៅតាមបណ្តាខេត្តមួយចំនួន ជាពិសេសស្រ្តីសម្រេចចិត្តមិនបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ដោយសារតែមិនមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការជួលកន្លែងស្នាក់នៅ។
- ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់សិស្សនៅជនបទដាច់ស្រយាលទទួលបានការសិក្សាបន្តធ្វើឱ្យក្មេងស្រីទម្លាក់ចោលការសិក្សា ព្រោះកត្តាសុវត្ថិភាព និងជីវភាព។

### ដំណោះស្រាយ៖

- ក្រសួងអប់រំត្រូវពង្រឹងគុណភាពលើការអប់រំ ហើយចុះត្រួតពិនិត្យជាក់លាក់លើការបង្រៀនរបស់គ្រូ កាត់បន្ថយការបង្រៀនគួរ ហើយងាកមកពង្រឹងគុណភាព ឬបន្ថែមម៉ោងនៃការបង្រៀននៅម៉ោងរដ្ឋ។
- បង្កើនវប្បធម៌អានសៀវភៅដោយមានបណ្ណាល័យនៅគ្រប់សាលា ជាពិសេសនៅតាមខេត្ត។
- បង្កើនទីតាំងសិក្សាក្រៅប្រព័ន្ធឱ្យបានកាន់តែទូលំទូលាយ និងនៅជិតកម្មការិនីរោងចក្រ និងសម្របសម្រួលម៉ោងសិក្សាដែលអំណោយផលដល់កម្មការិនីដែលលមានបំណងចង់បន្តការសិក្សាបណ្តើរ និងធ្វើការបណ្តើរ។
- ផ្តល់ការគាំពារ និងឧបត្ថម្ភដល់សិស្សក្រីក្រ ជាសម្ភារៈសិក្សា និងអាហាររូបករណ៍។
- បង្កើនកន្លែងស្នាក់នៅឥតគិតថ្លៃ និងបង្កើនចំនួនអាហាររូបករណ៍នៅថ្នាក់ឧត្តមសិក្សា ជាពិសេសក្មេងស្រី។
- រាជរដ្ឋាភិបាល និងក្រសួងទទួលបន្ទុកគួរតែបង្កើនកញ្ចប់ថវិកាជាតិក្នុងការបន្ថែមនូវចំនួនអាហារូបករណ៍តាមជំនាញដែលមាននៅក្នុងទីផ្សារការងារឱ្យបានច្រើន។
- រដ្ឋាភិបាល និងក្រសួងទទួលបន្ទុកគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីឱកាសអាហារូបករណ៍លើមុខជំនាញសិក្សាថ្នាក់ឧត្តមសិក្សា និងឱកាសអាហារូបករណ៍លើការស្នាក់នៅប្រកបដោយតម្លាភាព។

# តម្រូវការទី ១៣



## បង្កើន និងពន្លឿនកិច្ចអន្តរាគមន៍ជួយដល់ស្ត្រីរងគ្រោះ ជាពិសេសស្ត្រីមានពិការភាព ក្នុងការទទួលសេវាថែទាំសុខភាព និងគាំទ្រផ្លូវច្បាប់ឱ្យទាន់ពេលវេលា។

### បញ្ហាដែលកើតមានឡើង៖

- អាជ្ញាធរមួយចំនួនមិនបានដឹងពីតួនាទីរបស់ខ្លួនក្នុងការធ្វើអន្តរាគមន៍ជួយដល់ជនរងគ្រោះឱ្យទាន់ពេលវេលានោះទេ ជាពិសេសការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះជាស្ត្រី និងក្មេងស្រីដែលមានពិការភាពរាងកាយ និងសតិបញ្ញា។
- នៅពេលមានករណីរំលោភបំពានកើតឡើង សហគមន៍នៅមានភាពរើសអើង ដោយស្តីបន្ទោសលើជនរងគ្រោះ អាជ្ញាធរមួយចំនួនមិនយកចិត្តទុកដាក់ផ្តល់ការដោះស្រាយតាមផ្លូវច្បាប់ចំពោះករណីអំពើហិង្សាផ្អែកលើយេនឌ័រ។
- ការដាក់ទោសទណ្ឌចំពោះជនប្រព្រឹត្តទៅតាមច្បាប់នៅមានកម្រិត ហើយការការដោះស្រាយក្រៅប្រព័ន្ធតុលាការចំពោះបទល្មើសព្រហ្មទណ្ឌនៅតែបន្ត។

### ដំណោះស្រាយ៖

- ជំរុញឱ្យអាជ្ញាធរអនុវត្តតួនាទីទៅតាមផ្លូវច្បាប់ចំពោះករណីអំពើហិង្សាលើស្ត្រី ផ្តល់ការគាំទ្រឱ្យជនរងគ្រោះជាស្ត្រី និងកុមារីមានពិការភាពមានលទ្ធភាពដាក់ពាក្យបណ្តឹងទៅតុលាការ និង ទទួលបានសេវាថែទាំសុខភាពដោយមិនបង់ថ្លៃ និងជំរុញឱ្យមានការប្រើប្រាស់នូវសេចក្តីសម្រេចរដ្ឋបាល/ដីកាការពារ ដើម្បីការពារសុវត្ថិភាពជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។
- បង្កើនការបណ្តុះបណ្តាលជំនាញដល់អាជ្ញាធរពាក់ព័ន្ធអំពីរបៀបនៃការធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធិភាព ដើម្បីឆ្លើយតបទាន់ពេលវេលា ចំពោះរាល់ករណីអំពើហិង្សាផ្អែកលើយេនឌ័រ។
- ពន្លឿននិតីវិធីនៅតុលាការ ដើម្បីធានាថា មិនមានការពន្យារពេល ករណីអំពើហិង្សាផ្អែកលើយេនឌ័រ ដោយមិនមានការបង្វែរ ទៅរកការដោះស្រាយក្រៅប្រព័ន្ធតុលាការ។
- បែងចែកកញ្ចប់ថវិការដ្ឋ និងធានាថាថវិកានេះអាចប្រើប្រាស់បានដើម្បីគាំទ្រដល់ការចំណាយផ្សេងៗរបស់ជនរងគ្រោះក្នុងដំណើរការផ្លូវច្បាប់ទាំងស្រុងនៅតាមមូលដ្ឋាន និងនៅតុលាការ និងការទទួលបានសេវាព្យាបាលប្រកបដោយប្រសិទ្ធិភាព។

# តម្រូវការទី ១៤



## ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គម និងប្រកាសបេឡាជាតិសន្តិសុខសង្គម ដោយកែសម្រួលលក្ខខណ្ឌ តម្រូវឱ្យនិយោជក នៃសហគ្រាសនោះបានបង់ប្រាក់ភាគទាន ៩ដង ទើបកម្មករជាស្ត្រីមានផ្ទៃពោះទទួលបានប្រាក់ឧបត្ថម្ភ ៧០ភាគរយនៃប្រាក់ជាប់ភាគទាន។

### បញ្ហាដែលកើតមានឡើង៖

- ស្ថានភាពកូវីត-១៩ បានធ្វើឱ្យជីវភាពរបស់អ្នកងាយរងគ្រោះ ត្រូវបានធ្លាក់ក្នុងស្ថានភាពរងគ្រោះជាងមុនបញ្ហាថ្មីកើត ឡើងជាបន្ទុកធ្ងន់ដល់ពួកគេ។ តាមរយៈការបាត់បង់ចំណូល ការកើនឡើងបំណុល ការបាត់បង់ការងារ ការប្រែក្លាយពីកម្មករដែលស្ថិតនៅក្នុងប្រព័ន្ធ រួមមានកម្មករក្នុងវិស័យសេវាកម្សាន្ត សំណង់ ឡូតដ្ឋជាដើម ដែលទទួលបានការចុះបញ្ជីពីបេឡាជាតិសន្តិសុខសង្គមទៅជាកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធលែងទទួលការការពារ និងគាំពារសង្គមពីរបបសន្តិសុខសង្គមដោយសារតែកង្វះខាតនៃការធ្វើអធិការកិច្ចការងារនៅក្នុងគ្រឹះស្ថាន និងកន្លែងការងារទាំងនោះ។ យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវរួមមួយ ដែលធ្វើឡើងនៅក្នុងឆ្នាំ ២០២៣ «សម្ពាធក្រោមផ្ទៃរសាច់ក្រណាត់» បានរកឃើញថា មានកម្មករចំនួន៩១% ជំពាក់បំណុលគេ ហើយ ៧០% កើនបំណុលចាប់តាំងពីមានរាតត្បាតកូវីត១៩។ ស្ថិតក្នុងស្ថានភាពនេះផងដែរ និយោជកមួយចំនួនបានបិទសហគ្រាស ដោយមិនមានការទូទាត់សំណងដល់កម្មករ និងខ្លះទៀតបានរំសាយកម្មករ និងថ្នាក់ដឹកនាំសហជីពដោយយកហេតុផលនៃវិបត្តិកូវីដ១៩ បើទោះបីជាមានកិច្ចអន្តរាគមន៍ពីរាជរដ្ឋាភិបាលតាមរយៈការដាក់ចេញនូវគោលនយោបាយក្តីក៏នៅមានចំនួនតិចតួចដែលត្រូវគ្របដណ្តប់ និងកម្មករនិយោជិតទទួលបានជំនួយឧបត្ថម្ភពីកម្មវិធីរបស់រាជរដ្ឋាភិបាល ពីប្រព័ន្ធជំនួយសង្គមនេះ។
- លុះត្រាសាមីខ្លួនដែលជាកម្មករមានការដឹងជាក់ច្បាស់ភ្លាមនៅពេលខ្លួនមិនមានរដូវ ហើយធ្វើតេស្តទឹកនោមភ្លាម ឃើញថាមានកូនត្រូវប្រញាប់រត់ទៅប្រាប់រដ្ឋបាលរបស់ក្រុមហ៊ុន ដើម្បីចាប់ផ្តើមជូនដំណឹងទៅបេឡាជាតិសន្តិសុខសង្គមក្នុងការបង់ភាគទានបន្ថែមភ្លាមៗ។

- ស្ថានភាពជាក់ស្តែងកម្មករអាចធ្វើការតេស្តទឹកនោមយឺតពេល ២ ខែ ឬទៅ ៣ ខែ ក្រោយពេលបាត់រដូវ ដូច្នេះ ភាពយឺតយ៉ាវមិនបានទទួលបានការគាំពារពីបេឡាជាតិសន្តិសុខសង្គម លុះត្រាបានបង់ភាគទាន ៩ ដងជាប់លាប់សិនក្នុងរយៈពេល១២ ខែ (យោងលក្ខខណ្ឌរបស់ ប.ស.ស.)។
- បើទោះជាច្បាប់ស្តីពី របបសន្តិសុខសង្គម ប្តូរពីបង់ភាគទានពី ៩ខែជាប់លាប់ មកបង់ជា ៩ ដង ក៏មិនមានការឆ្លើយតបទៅនឹងស្ថានភាពកម្មករនិយោជិតដែលជាស្ត្រីដែរ ព្រោះការបង់ភាគទានទៅបេឡាជាតិសន្តិសុខសង្គមគឺរដ្ឋបាលរបស់ក្រុមហ៊ុនមិនមែនបង់ប្រចាំថ្ងៃ ឬអាទិត្យទេ។
- ការរើសអើងដោយប្រយោលចំពោះស្ត្រីមានផ្ទៃពោះពីនិយោជក ក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាការងារបានធ្វើឱ្យនិយោជកគេចវេសការទទួលខុសត្រូវក្នុងការបង់ភាគទាន ៩ ខែ ជាប់លាប់ ឱ្យបេឡាជាតិសន្តិសុខសង្គម។
- ការប្រើប្រាស់កិច្ចសន្យាខ្លី ដែលជាឫសគល់នៃចំណោទបញ្ហា ដែលបណ្តាលឱ្យស្ត្រីងាយរងនូវការរើសអើងដោយប្រយោលនៅកន្លែងការងារ នៅពេលដែលមានផ្ទៃពោះការបញ្ចប់កិច្ចសន្យាដែលធ្វើឱ្យស្ត្រីត្រូវមានជម្រើសយកកូន ឬបន្តធ្វើការងារ ។

## ដំណោះស្រាយ៖

- លុបចេញនូវលក្ខខណ្ឌដែលតម្រូវឱ្យមានការបង់ភាគទានរហូតដល់ទៅ ៩ ដងនៃរបបថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះ ទើបទទួលបានប្រាក់ឧបត្ថម្ភចំនួន ៧០% នៃប្រាក់ជាប់ភាគទាន ព្រោះលក្ខខណ្ឌនេះ មិនមែនជាលក្ខខណ្ឌការពារកម្មករពិតប្រាកដ ឬអ្នកងាយរងគ្រោះនោះទេ។
- ផ្តល់ការការពារបិតុភាព (ការឈប់សម្រាកសម្រាកឪពុក) ដូចលក្ខខណ្ឌម្តាយដែរ ទើបនិយោជកជួលស្ត្រី និងបុរសមានកាតព្វកិច្ចដូចគ្នា ដែលកាត់បន្ថយរើសអើង និងកាត់បន្ថយហានិភ័យចំពោះកម្មករស្ត្រី លើសពីនេះ ស្ត្រីនិងបុរស នៅតែបន្តការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងសង្គមជាតិ។
- របបថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះគួរទទួលបានការគាំពារជាពិសេស ហើយមានប្រសិទ្ធភាពភ្លាម គឺទទួលបាន ៧០% នៃប្រាក់ជាប់ភាគទាន នៅពេលដែលចាប់ផ្តើមចូលបំពេញការងារ ដោយមិនត្រូវរង់ចាំរហូតដល់បានបង់ភាគទាន ៩ ដងនោះឡើយ ហើយលក្ខខណ្ឌនេះក៏ត្រូវដាក់បញ្ចូលផងដែរចំពោះបុរសដែលមានប្រពន្ធចុះសំបុត្រអាពាហ៍ពិពាហ៍។
- ដាក់ទោសទណ្ឌទាំងពិន័យជាសាច់ប្រាក់ រួមទាំងទោសព្រហ្មទណ្ឌដោយមិនមានការលើកលែងចំពោះការរើសអើង ទាំងឡាយណា ដោយប្រយោល ឬផ្ទាល់ ពីសំណាក់និយោជកមកលើកម្មករស្ត្រីមានផ្ទៃពោះ និងសម្រាកមាតុភាព។

# តម្រូវការទី ១៥



## ពង្រីកទីផ្សារការងារក្នុងស្រុកបង្កើនជំនាញថ្មី រួមទាំងពន្លឿនការអនុវត្តគោលនយោបាយ ផ្តល់ប្រាក់ឧបត្ថម្ភ អំឡុងពេលបាត់បង់ ប្រាក់ចំណូល ឬអត់ការងារធ្វើ ជាពិសេស សម្រាប់ស្ត្រី និងយុវជន។

### បញ្ហាដែលកើតមានឡើង៖

- វិស័យឯកជនមិនមានទំនួលខុសត្រូវក្នុងវិបត្តិកូវីដ-១៩ និយោជកបានយកឱកាសរំសាយ និង បញ្ឈប់ការងាររួម បើទោះបី សហគ្រាស គ្រឹះស្ថានទាំងនោះមិនក្ស័យធនក៏ដោយ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនខ្វះកម្លាំងកម្មករ ហើយថែមទាំងត្រូវការកម្លាំងកម្មករធ្វើការងារបន្តមកទៀត។
- ស្ថានភាពនេះកម្មករដែលធ្វើការទទួលបានការគាំពារក្នុងប្រព័ន្ធបានធ្លាក់ក្នុងស្ថានភាពក្រៅប្រព័ន្ធ ដោយមិនទទួលបានការចុះបញ្ជីជាមួយបេឡាជាតិសន្តិសុខសង្គម និងការងារមានគ្រោះថ្នាក់មិន មានប្រាក់ចំណូលទៀងទាត់។
- ប្រជាពលរដ្ឋអត់ការងារធ្វើច្រើនត្រូវបានវិស័យឯកជនឆក់ឱកាស ហើយកម្មករទទួលបានប្រាក់ ឈ្នួលទាបដោយសារទីផ្សារការងារចង្អៀត។
- បំណុល រួមទាំងការប្រាក់មានការកើនឡើង។
- ការផ្តល់នូវជំនាញ តែប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលចូលវគ្គបណ្តុះបណ្តាលបង្កើននូវជំនាញគឺយុវកម្មករ ត្រូវការប្រាក់សម្រាប់ជួយគាំទ្រដល់ជីវភាពចាំបាច់ប្រចាំថ្ងៃដែលជាកត្តាឧបសគ្គមួយធ្វើឱ្យយុវកម្មករ មួយចំនួនបោះបង់ការអភិវឌ្ឍជំនាញ។

### ដំណោះស្រាយ៖

- បង្កើនការទាញវិស័យឯកជនឱ្យមានទំនួលខុសត្រូវក្នុងសង្គម រដ្ឋាភិបាលត្រូវពិនិត្យមើលស្ថានភាព របស់ក្រុមហ៊ុនទាំងនោះ មិនអនុញ្ញាតឱ្យក្រុមហ៊ុន ឬវិស័យឯកជនបកស្រាយ ឬឆក់ឱកាសលើស្ថានភាព អ្នករងគ្រោះដែលកំពុងរងគ្រោះខ្លាំងក្នុងស្ថានភាពវិបត្តិការរីករាលដាលនៃមេរោគផ្សេងៗនោះទេ។

- ធានាដល់ការរស់នៅរបស់ពលរដ្ឋប្រកបដោយជីវិតថ្លៃថ្នូរក្នុងនាមជាមនុស្ស ដោយការគាំទ្រជាសាច់ប្រាក់ក្នុងអំឡុងពេលដែលកម្មករបាត់បង់ការងារជាបណ្ដោះអាសន្ន។
- ក្នុងអំឡុងពេលយុវកម្មករចូលរួមវគ្គបណ្ដុះបណ្ដាលសមត្ថភាពលើជំនាញ រាជរដ្ឋាភិបាលគួរបង្កើននូវសាច់ប្រាក់ឧបត្ថម្ភ ដើម្បីឱ្យពួកគេចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញដោយពេញលេញ និងយកចិត្តទុកដាក់ ។
- ដើម្បីឆ្លើយតបទីផ្សារការងារថ្មី ផ្ដល់ជំនាញបន្ថែមក្នុងអំឡុងពេលទទួលបានកម្មវិធី «ការឧបត្ថម្ភសាច់ប្រាក់អត់ការងារធ្វើ» ទឹកប្រាក់នេះគឺជាទឹកប្រាក់ដែលអាចយកមកចាត់ចែង និងដោះស្រាយជីវភាពប្រចាំថ្ងៃ។
- ដំណោះស្រាយនេះរដ្ឋបានធានាដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ដោយមិនអនុញ្ញាតឱ្យវិស័យឯកជនរួមមាន សហគ្រាស គ្រឹះស្ថាន បញ្ឈប់ ឬរំសាយកម្មករ ដោយសេរីក្នុងរូបភាពឆក់ឱកាសក្នុងស្ថានភាពណាមួយ។



# តម្រូវការទី ១៦

## ពន្លឿនការចុះបញ្ជីពលរដ្ឋ ដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការធ្វើវិសោធនកម្មប្រកាសអន្តរក្រសួង ៤០៤។



### បញ្ហាដែលកើតមានឡើង៖

- ការកំណត់និយមន័យដែលមាននៅក្នុងប្រកាសដែលចេញដោយអន្តរក្រសួងមិនមានភាពស៊ីចង្វាក់គ្នាជាមួយច្បាប់ស្តីពីរបបសន្តិសុខសង្គមដែលចេញកាលពីឆ្នាំថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

- ប្រកាសអន្តរក្រសួង ៤០៤ បានចែងថា «កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាកម្មករដែលធ្វើការតិចជាង ៨ ម៉ោង ក្នុងមួយសប្តាហ៍»។ និយមន័យនេះ មិនឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងរបស់ពលរដ្ឋខ្មែរដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្បិតពលរដ្ឋខ្មែរភាគច្រើនធ្វើការងារច្រើនជាង ៨ ម៉ោងក្នុងមួយសប្តាហ៍។ ប្រកាសនេះបានរារាំងឱ្យពលរដ្ឋធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធរាប់ម៉ឺននាក់ ជាពិសេសស្ត្រីលក់ដូរតាមដងផ្លូវ អ្នករត់កង់បី និងបុគ្គលិកផ្នែកកម្សាន្ត មិនអាចទទួលបានអត្ថប្រយោជន៍ និងការគាំពារពីគោលនយោបាយកិច្ចគាំពារសង្គមមានដូចជា កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ម្តាយ និងទារក ប័ណ្ណសមាជិក ប.ស.ស. និងកម្មវិធីជំនួយសាច់ប្រាក់សម្រាប់កម្មករនិយោជិតដែលពេលបាត់បង់ការងារ និងគ្មានការងារធ្វើកំឡុងពេលកូវីដ-១៩ ជាដើម។

- កម្មករផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab..) និងដឹកជញ្ជូនអាហារដល់ផ្ទះ (Food Panda...) មានការចំណាយទុនច្រើនក្នុងការភ្ជាប់សេវាកម្មនេះរួមមាន ការទិញទូរស័ព្ទខ្លួនឯង និងទិញកង់បីបង់រំលោះ ធ្វើការច្រើនម៉ោងដើម្បីទទួលបានប្រាក់កំរៃជើងសារពីក្រុមហ៊ុន។

- ក្រុមហ៊ុនផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab..) និងដឹកជញ្ជូនអាហារដល់ផ្ទះ (Food Panda...) ដែលភ្ជាប់ជាមួយកម្មវិធី (App) មានបុគ្គលិករាប់ពាន់នាក់ទូទាំងប្រទេស ប៉ុន្តែក្រុមហ៊ុនមិនទាន់បានចុះបញ្ជី និងបង់វិភាគទាន ប.ស.ស. ជូនដល់បុគ្គលិកខ្លួនឡើយ។

## ដំណោះស្រាយ៖

- រដ្ឋាភិបាលពិនិត្យធ្វើនិរាករណ៍ប្រកាសអន្តរក្រសួង ៤០៤ ដើម្បីបង្កភាពងាយស្រួល ដល់ពលរដ្ឋធ្វើការសេដ្ឋកិច្ច ប្រព័ន្ធចុះបញ្ជី និងទទួលបានការការពារ និងអត្ថប្រយោជន៍ពីគោលនយោបាយគាំពារសង្គម ជាពិសេសការទទួលបានប័ណ្ណសមធ៌ម (ឬប័ណ្ណក្រីក្រ) និងប័ណ្ណសមាជិក ប.ស.ស.។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គមត្រូវពិចារណា និងបង្កយន្តការដែលកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចបង់វិភាគទាន (ដោយមានវិភាគទានបន្ថែមពីរដ្ឋ) ដើម្បីទទួលអត្ថប្រយោជន៍ និងប័ណ្ណសមាជិក ប.ស.ស.។

- ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានា និងបង្កភាពងាយស្រួលជូនដល់កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីទទួលបានឯកសារអត្តសញ្ញាណ (ឧ.ទា លិខិតបញ្ជាក់ទីលំនៅ ឬឯកសារយោងផ្សេងៗ) ដើម្បីផ្តល់ភាពងាយស្រួលដល់ពួកគេស្នើសុំប័ណ្ណសមធ៌ម (ឬប័ណ្ណក្រីក្រ) និងប័ណ្ណសមាជិក ប.ស.ស.។

- ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ត្រូវអនុវត្តន៍ច្បាប់របបសន្តិសុខសង្គម ដែលតម្រូវឱ្យក្រុមហ៊ុនផ្នែកដឹកជញ្ជូនភ្ញៀវ (PassApp, Grab..) និងដឹកជញ្ជូនអាហារតាមផ្ទះ (Food Panda...) ដែលភ្ជាប់ជាមួយកម្មវិធី (App) របស់ក្រុមហ៊ុនចុះបញ្ជីការ និងបង់ភាគទាន ប.ស.ស. សម្រាប់បុគ្គលិករបស់ខ្លួន ដែលកំពុងធ្វើការដោយគ្មានការគាំពារសង្គម។



# បញ្ជីឈ្មោះអង្គការសង្គមស៊ីវិលដែលគាំទ្រញត្តិនេះរួមមាន៖

១. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា
២. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ
៣. សហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
៤. សហព័ន្ធសហជីពកម្ពុជា
៥. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៦. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា
៧. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៨. សហព័ន្ធសហជីពសេរីឯករាជ្យ
៩. សហព័ន្ធសហជីពឯករាជ្យ
១០. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស
១១. បណ្ដាញយុវជនកម្ពុជា
១២. អង្គការសមធម៌កម្ពុជា
១៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
១៤. អង្គការសមាគមធាងត្នោត
១៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
១៦. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ
១៧. អង្គការក្លាហាន
១៨.គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ
១៩. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
២០. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
២១. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា
២២. សមាគមស្ត្រីជនបទដើម្បីក្សេត្របរិស្ថាន
២៣. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង
២៤. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
២៥. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា

# យុទ្ធនាការ ១៦ ថ្ងៃ

លើកកម្ពស់សិទ្ធអំណាចស្ត្រី និងក្មេងស្រី
ដើម្បីរួចផុតពីការបៀតបៀនគ្រប់ទម្រង់